| 2 | តាវកាលិកលំហែមាតុភាព | | 0 |
| សរុប | | | 2 |

ប្រភព៖ នាយកដ្ឋានតាវកាលិកសន្តិសុខសង្គម

**តារាងទី៦០៖ បច្ចុប្បន្នភាពសមាជិកទទួលតាវកាលិក**

| បរិយាយ | សមាជិកទទួលតាវកាលិក (នាក់) | |
|---|---|---|
| | សរុប | ស្រី |
| ឆ្នាំ2023 | 2 | 2 |

ប្រភព៖ នាយកដ្ឋានតាវកាលិកសន្តិសុខសង្គម

**តារាងទី៦១៖ ការចំណាយថវិកាទូទាត់សេវាមូលដ្ឋានសុខាភិបាល និងបើកផ្តល់តាវកាលិក**

| ល.រ | បរិយាយ | ឯកតា | ឆ្នាំ2023 |
|---|---|---|---|
| 1. ការចំណាយតាមប្រភេទតាវកាលិក | | លានរៀល | 1.04 |
| 1.1 | តាវកាលិកសេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រ (ករណីសង្គ្រោះបន្ទាន់) | | 1.04 |
| 1.2 | តាវកាលិកលំហែមាតុភាព | | 0.00 |
| 2. មន្ទីរពេទ្យផ្លូវការ | | | 479.50 |
| សរុប(1+2) | | | 480.54 |

ប្រភព៖ នាយកដ្ឋានគ្រប់គ្រងថវិកាហិរញ្ញវត្ថុនិងគណនេយ្យ

### ❖ ការងារស្តារនីតិសម្បទា

**តារាងទី៦២៖ ការផ្តល់ និងការចំណាយសេវាស្តារនីតិសម្បទាផ្នែកវេជ្ជសាស្ត្រ**

| ល.រ | បរិយាយ | ឯកតា | ឆ្នាំ2023 | |
|---|---|---|---|---|
| | | | សរុប | ស្រី |
| 1 | ការផ្តល់សេវាស្តារផ្នែកវេជ្ជសាស្ត្រ | ករណី | 0 | 0 |
| 2 | ការចំណាយផ្នែកវេជ្ជសាស្ត្រ | លានរៀល | 1.57 | |

ប្រភព៖ នាយកដ្ឋានស្តារនីតិសម្បទា និងនាយកដ្ឋានគ្រប់គ្រងថវិកាហិរញ្ញវត្ថុនិងគណនេយ្យ

សម្គាល់៖ ក្នុងឆ្នាំ២០២៣ នេះ ការផ្តល់សេវាផ្នែកវេជ្ជសាស្ត្រពុំមាន មានតែការចំណាយទិញឧបករណ៍ជំនួយដាក់ចូលឃ្លាំង។

## គ. ការអនុវត្តរបបសន្តិសុខសង្គមផ្នែកប្រាក់សោធន

បេឡាជាតិសន្តិសុខសង្គមបានចាប់ផ្តើមអនុវត្តរបបសន្តិសុខសង្គមផ្នែកប្រាក់សោធន សម្រាប់កម្មករនិយោជិតចាប់ពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២២ និងបានដាក់ឱ្យជាប់ភាគទានចាប់ពីថ្ងៃទី១ ខែតុលា ឆ្នាំ២០២២។

### គ.១. សោធនជាកាតព្វកិច្ច

#### គ.១.១. ការងារបញ្ជិកា និងភាគទាន

#### ❖ ការងារបញ្ជិកា

បច្ចុប្បន្នភាពក្នុងឆ្នាំ២០២៣ នេះ មានសហគ្រាស គ្រឹះស្ថានសរុប ១៨ ២៣០សហគ្រាស និងមានសមាជិកសរុប ១ ៤៩៤ ៥៧៦នាក់ ស្រី ៩២០ ១០៩នាក់។

**តារាងទី៦៣៖ បច្ចុប្បន្នភាពសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត**

| បរិយាយ | សរុប | | | ថ្នាក់កណ្តាល | | | ថ្នាក់ខេត្ត | | |
|---|---|---|---|---|---|---|---|---|---|
| | សហគ្រាស | សមាជិក | ស្រី | សហគ្រាស | សមាជិក | ស្រី | សហគ្រាស | សមាជិក | ស្រី |
| ឆ្នាំ2022 | 13,976 | 1,434,407 | 895,534 | 7,898 | 723,917 | 414,312 | 6,078 | 710,490 | 481,222 |
| ឆ្នាំ2023 | 18,230 | 1,494,576 | 920,109 | 9,971 | 733,813 | 411,733 | 8,259 | 760,763 | 508,376 |
| បម្រែបម្រួល (± %) | 30.44% | 4.19% | 2.74% | 26.25% | 1.37% | -0.62% | 35.88% | 7.08% | 5.64% |

ប្រភព៖ នាយកដ្ឋានបញ្ជិកានិងភាគទាន

**តារាងទី៦៤៖ សហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតចុះបញ្ជិកាថ្មី**

| បរិយាយ | សរុប | | | ថ្នាក់កណ្តាល | | | ថ្នាក់ខេត្ត | | |
|---|---|---|---|---|---|---|---|---|---|
| | សហគ្រាស | សមាជិក | ស្រី | សហគ្រាស | សមាជិក | ស្រី | សហគ្រាស | សមាជិក | ស្រី |
| ឆ្នាំ2022 | 603 | 44,725 | 21,993 | 330 | 24,308 | 11,652 | 273 | 20,417 | 10,341 |
| ឆ្នាំ2023 | 4,957 | 197,903 | 96,687 | 2,571 | 98,539 | 46,963 | 2,386 | 99,364 | 49,724 |
| បម្រែបម្រួល (± %) | 722.06% | 342.49% | 339.63% | 679.09% | 305.38% | 303.05% | 773.99% | 386.67% | 380.84% |

ប្រភព៖ នាយកដ្ឋានបញ្ជិកានិងភាគទាន

### ❖ ការងារភាគទាន

ក្នុងឆ្នាំ២០២៣ នេះ ប.ស.ស. បានដាក់ឱ្យសហគ្រាស គ្រឹះស្ថានជាប់ភាគទានជាមធ្យមចំនួន ១៥ ៣១១សហគ្រាស ក្នុងនោះសហគ្រាស គ្រឹះស្ថានបានបង់ភាគទានជាមធ្យមមានចំនួន ១៤ ៣៤៨សហគ្រាស ស្មើនឹង ៩៣,៧១% សហគ្រាសបានបង់ភាគទានទាន់ពេលវេលា និងមានកម្មករនិយោជិតបានបង់ភាគទានសរុបជាមធ្យមចំនួន ១ ៣៩៦ ៣៨០នាក់ ស្រី ៨៦៤ ៩០៥នាក់។ ដោយឡែកសហគ្រាសប្រមាណជា ៦,២៩% មានការយឺតយូរ ឬបានធ្វើការស្នើសុំពន្យារពេលក្នុងការបង់ភាគទាន។

**តារាងទី៦៥៖ ចំនួនសហគ្រាស គ្រឹះស្ថាន និងសមាជិកបានបង់ភាគទាន**

| បរិយាយ | សហគ្រាស ជាប់ភាគទាន (មធ្យមភាគ) | សហគ្រាស បានបង់ភាគទាន (មធ្យមភាគ) | សមាជិក បានបង់ភាគទាន (មធ្យមភាគ) | | ភាគទាន (លានរៀល) | ភាគរយសហគ្រាស បានបង់ភាគទាន |
|---|---|---|---|---|---|---|
| | | | សរុប | ស្រី | | |
| ឆ្នាំ2022 | 13,481 | 11,576 | 1,345,320 | 844,255 | 53,956.12 | 85.87% |
| ឆ្នាំ2023 | 15,311 | 14,348 | 1,396,380 | 864,905 | 685,048.50 | 93.71% |
| បម្រែបម្រួល (± %) | 13.57% | 23.95% | 3.80% | 2.45% | 1,169.64% | 9.13% |

ប្រភព៖ នាយកដ្ឋានបញ្ជិកានិងភាគទាន និងនាយកដ្ឋានគ្រប់គ្រងថវិកាហិរញ្ញវត្ថុនិងគណនេយ្យ

**ក្រាហ្វិកទី៩. ចំនួនសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតបានបង់ភាគទាន**




ប្រភព៖ នាយកដ្ឋានបញ្ជិកានិងភាគទាន និងនាយកដ្ឋានគ្រប់គ្រងថវិកាហិរញ្ញវត្ថុនិងគណនេយ្យ

### គ.១.២. ការងារតាវកាលិក

នៅក្នុងឆ្នាំ២០២៣ នេះ ប.ស.ស. បានទទួលការទាមទារតាវកាលិកវិភាជន៍ជរាភាពសរុប ២ឯកសារ ដែលមានសមាជិកទាមទារតាវកាលិកចំនួន ២នាក់ ស្រី ១នាក់ និងបានបើកផ្តល់តាវកាលិកជូនសមាជិកចំណាយជាទឹកប្រាក់សរុប ៧២៥ ១០០រៀល។

### គ.២. សោធនដោយស្ម័គ្រចិត្ត

- **ការងារបញ្ជិកា និងភាគទាន**

ក្នុងឆ្នាំ២០២៣ នេះ ប.ស.ស. បានចុះបញ្ជីសមាជិកផ្នែកប្រាក់សោធនដោយស្ម័គ្រចិត្តមានចំនួន ៤ ៦៦៦នាក់ ស្រី ១ ៩១៨នាក់ មានបច្ចុប្បន្នភាពសមាជិកសរុប ៤ ៣៣៨នាក់ ស្រី ១ ៧៥៨នាក់ សមាជិកចុះបញ្ជិកាថ្មីមានចំនួន ២ ២៨២នាក់ ស្រី ១ ០៥២នាក់ និងសមាជិកបានបង់ភាគទានសរុប ២ ៩៩៦នាក់ ស្រី ១ ១៦២នាក់ ដោយទទួលបានការបង់ភាគទានសរុប ១ ៦៥០,៨៩លានរៀល។

**តារាងទី៦៦៖ សមាជិកចុះបញ្ជិកា**

| បរិយាយ | សរុប | | ថ្នាក់កណ្តាល | | ថ្នាក់ខេត្ត | |
|---|---|---|---|---|---|---|
| | សមាជិក | ស្រី | សមាជិក | ស្រី | សមាជិក | ស្រី |
| ឆ្នាំ2022 | 2,384 | 866 | 542 | 242 | 1,842 | 624 |
| ឆ្នាំ2023 | 4,666 | 1,918 | 1,547 | 775 | 3,119 | 1,143 |
| បម្រែបម្រួល (± %) | 95.72% | 121.48% | 185.42% | 220.25% | 69.33% | 83.17% |

ប្រភព៖ នាយកដ្ឋានបញ្ជិកានិងភាគទាន

**តារាងទី៦៧៖ បច្ចុប្បន្នភាពសមាជិក**

| បរិយាយ | សរុប | |
|---|---|---|
| | សមាជិក | ស្រី |
| ឆ្នាំ2022 | 2,267 | 823 |
| ឆ្នាំ2023 | 4,338 | 1,758 |
| បម្រែបម្រួល (±%) | 91.35% | 113.61% |

ប្រភព៖ នាយកដ្ឋានបញ្ជិកានិងភាគទាន

**តារាងទី៦៨៖ ចំនួនសមាជិកចុះបញ្ជិកាថ្មី**

| បរិយាយ | សរុប | | ថ្នាក់កណ្តាល | | ថ្នាក់ខេត្ត | |
|---|---|---|---|---|---|---|
| | សមាជិក | ស្រី | សមាជិក | ស្រី | សមាជិក | ស្រី |
| ឆ្នាំ2022 | 2,384 | 866 | 542 | 242 | 1,842 | 624 |
| ឆ្នាំ2023 | 2,282 | 1,052 | 1,005 | 533 | 1,277 | 519 |
| បម្រែបម្រួល (± %) | -4.28% | 21.48% | 85.42% | 120.25% | -30.67% | -16.83% |

ប្រភព៖ នាយកដ្ឋានបញ្ជិកានិងភាគទាន

# ឃ. ការអនុវត្តកម្មវិធីជំនួយសង្គម

## ឃ.១. កម្មវិធីផ្តល់ប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលសម្រាប់សមាជិក ប.ស.ស. ជាស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ

**តារាងទី៧០៖ កម្មវិធីផ្តល់ប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលសម្រាប់សមាជិក ប.ស.ស. ជាស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ**

| បរិយាយ | ឯកតា | ឆ្នាំ2023 | | | |
|---|---|---|---|---|---|
| | | ម្តាយ | កូន | ប្រាក់ឧបត្ថម្ភ (រៀល) | ប្រាក់ឧបត្ថម្ភ (លានរៀល) |
| មុនសម្រាល | ចំនួន (ID) | 47,862 | - | 80,000.00 | 5,703.44 |
| | ចំនួន (លើក) | 71,293 | - | | |
| សរុបពេលសម្រាល | | 17,476 | 17,602 | - | 14,031.20 |
| ពេលសម្រាល | កូន១ | 17,350 | 17,350 | 800,000.00 | 13,880.00 |
| | កូន២ | 126 | 252 | 1,200,000.00 | 151.20 |
| | កូន៣ | 0 | 0 | 1,600,000.00 | - |
| | កូន៤ | 0 | 0 | 2,000,000.00 | - |
| ក្រោយសម្រាល | ចំនួន (ID) | 23,250 | - | 80,000.00 | 3,362.88 |
| | ចំនួន (លើក) | 42,036 | - | | |
| ចាក់វ៉ាក់សាំងកូន | ចំនួន (ID) | 30,487 | 30,802 | 80,000.00 | 3,420.16 |
| | ចំនួន (លើក) | - | 42,752 | | |
| សរុប | | | | | 26,517.68 |

ប្រភព៖ នាយកដ្ឋានតាវកាលិកសន្តិសុខសង្គម និងនាយកដ្ឋានគ្រប់គ្រងថវិកាហិរញ្ញវត្ថុនិងគណនេយ្យ (ទិន្នន័យលម្អិតសូមមើលក្នុងតារាងឧបសម្ព័ន្ធទី៦)

សម្គាល់៖ ID គឺការកំណត់អត្តសញ្ញាណរបស់ម្តាយ (ដោយគ្មានស្ទួន) ចំណែកចំនួនលើកសំដៅដល់ការប្រើប្រាស់សេវា។

**តារាងទី៧១៖ ការបើកផ្តល់ប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលសម្រាប់កម្មករនិយោជិតជាស្ត្រីពេលសម្រាលកូន**

| កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូនសរុប | | | | | | |
|---|---|---|---|---|---|---|
| បរិយាយ | ចំនួនស្ត្រីសម្រាលកូន (នាក់) | | | | ចំនួនកូនសរុប (នាក់) | ទឹកប្រាក់សរុប (លានរៀល) |
| | ស្ត្រីសម្រាលកូនសរុប | ស្ត្រីកូនភ្លោះពីរ | ស្ត្រីកូនភ្លោះបី | ស្ត្រីកូនភ្លោះ បួន | | |
| ឆ្នាំ2022 | 55,801 | 379 | 4 | 0 | 56,188 | 22,475.20 |
| ឆ្នាំ2023 | 45,402 | 313 | 4 | 1 | 45,726 | 18,290.40 |
| បម្រែបម្រួល (± %) | -18.64% | -17.41% | 0.00% | 100.00% | -18.62% | -18.62% |
| ការបើកផ្តល់ប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលសម្រាប់សមាជិក ប.ស.ស. តាមរបបភាគទានកាតព្វកិច្ច | | | | | | |
| បរិយាយ | ចំនួនស្ត្រីសម្រាលកូន (នាក់) | | | | ចំនួនកូនសរុប (នាក់) | ទឹកប្រាក់សរុប (លានរៀល) |
| | ស្ត្រីសម្រាលកូនសរុប | ស្ត្រីកូនភ្លោះពីរ | ស្ត្រីកូនភ្លោះបី | ស្ត្រីកូនភ្លោះ បួន | | |
| ឆ្នាំ2022 | 55,712 | 379 | 4 | 0 | 56,099 | 22,439.60 |
| ឆ្នាំ2023 | 45,271 | 312 | 4 | 1 | 45,594 | 18,237.60 |
| បម្រែបម្រួល (± %) | -18.74% | -17.68% | 0.00% | 100.00% | -18.73% | -18.73% |
| ការបើកផ្តល់ប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលសម្រាប់កម្មករនិយោជិតជាស្ត្រីក្រៅប្រព័ន្ធ | | | | | | |
| បរិយាយ | ចំនួនស្ត្រីសម្រាលកូន (នាក់) | | | | ចំនួនកូនសរុប (នាក់) | ទឹកប្រាក់សរុប (លានរៀល) |
| | ស្ត្រីសម្រាលកូនសរុប | ស្ត្រីកូនភ្លោះពីរ | ស្ត្រីកូនភ្លោះបី | ស្ត្រីកូនភ្លោះ បួន | | |
| ឆ្នាំ2022 | 89 | 0 | 0 | 0 | 89 | 35.60 |
| ឆ្នាំ2023 | 131 | 1 | 0 | 0 | 132 | 52.80 |
| បម្រែបម្រួល (± %) | 47.19% | 100.00% | 0.00% | 0.00% | 48.31% | 48.31% |

ប្រភព៖ នាយកដ្ឋានតាវកាលិកសន្តិសុខសង្គម និងនាយកដ្ឋានគ្រប់គ្រងថវិកាហិរញ្ញវត្ថុនិងគណនេយ្យ (ទិន្នន័យលម្អិតសូមមើលក្នុងតារាងឧបសម្ព័ន្ធទី៧)

ក្រាហ្វិកទី១០. ការបើកផ្តល់ប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលសម្រាប់កម្មករនិយោជិតជាស្ត្រីពេលសម្រាលកូន




ប្រភព៖ នាយកដ្ឋានតាវកាលិកសន្តិសុខសង្គម និងនាយកដ្ឋានគ្រប់គ្រងថវិកាហិរញ្ញវត្ថុនិងគណនេយ្យ

### ឃ.២. ការចុះបញ្ជី និងផ្តល់ប័ណ្ណមូលនិធិសមធម៌សុខាភិបាល

ប.ស.ស. ទទួលបន្ទុកចុះបញ្ជី និងផ្តល់ប័ណ្ណមូលនិធិសមធម៌សុខាភិបាលចាប់ពីឆ្នាំ២០១៨ រហូតមកដល់ឆ្នាំ២០២៣នេះដែលបច្ចុប្បន្នមានស្ថាប័ន សហគ្រាស គ្រឹះស្ថានសរុប ២៧២សហគ្រាស មានចំនួន ៩៩ ៤១៧នាក់ ស្រី ២០ ៣៣៥នាក់ ក្នុងនោះមាន៖

- ក្រុមប្រឹក្សាឃុំ សង្កាត់ ប្រធាន អនុប្រធាន និងសមាជិកភូមិមានចំនួន ២២៩ស្ថាប័ន សរុប ៥៧ ២២៤នាក់ ស្រី ១៤ ១៨៧នាក់
- កីឡាករ និងកីឡាការិនីមានចំនួន ១សមាគម សរុប ១ ១៨៣នាក់ ស្រី ៣៣៨នាក់
- សមាគមកម្មករស៊ីក្លូ អ្នករត់ម៉ូតូឌុប និងម៉ូតូកង់បីមានចំនួន ៣៧សមាគម សរុប ៤០ ៣៤៥នាក់ ស្រី ៥ ៤៨៥នាក់
- កម្មករនិយោជិតក្រៅប្រព័ន្ធផ្សេងៗមានចំនួន ៥សមាគម សរុប ៦៦៥នាក់ ស្រី ៣២៥នាក់។

**តារាងទី៧២៖ បច្ចុប្បន្នភាពសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតបានចុះបញ្ជិកាក្រៅប្រព័ន្ធ**

| បរិយាយ | សរុប | | | ថ្នាក់កណ្តាល | | | ថ្នាក់ខេត្ត | | |
|---|---|---|---|---|---|---|---|---|---|
| | សហគ្រាស | សមាជិក | ស្រី | សហគ្រាស | សមាជិក | ស្រី | សហគ្រាស | សមាជិក | ស្រី |
| ឆ្នាំ2022 | 947 | 96,198 | 20,828 | 223 | 39,245 | 5,912 | 724 | 56,953 | 14,916 |
| ឆ្នាំ2023 | 272 | 99,417 | 20,335 | 42 | 41,905 | 6,047 | 230 | 57,512 | 14,288 |
| បម្រែបម្រួល (± %) | -71.28% | 3.35% | -2.37% | -81.17% | 6.78% | 2.28% | -68.23% | 0.98% | -4.21% |

ប្រភព៖ នាយកដ្ឋានបញ្ជិកានិងភាគទាន (ទិន្នន័យលម្អិតសូមមើលក្នុងតារាងឧបសម្ព័ន្ធទី៨)

## ង. ការអភិវឌ្ឍសមត្ថភាពស្ថាប័ន

### ង.១. ក្រុមប្រឹក្សាភិបាលនៃបេឡាជាតិសន្តិសុខសង្គម

ក្រុមប្រឹក្សាភិបាលនៃបេឡាជាតិសន្តិសុខសង្គម តែងតាំងដោយអនុក្រឹត្យលេខ៧១៣ អនក្រ.តត ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២០ និងបានអញ្ជើញចូលរួមក្នុងពិធីប្រកាសសមាសភាពក្រុមប្រឹក្សាភិបាលនៃ ប.ស.ស. អាណត្តិទី១ នៅថ្ងៃទី៦ ខែសីហា ឆ្នាំ២០២២ មានបេសកកម្មដឹកនាំតម្រង់ទិសការអនុវត្តសកម្មភាព

ការងារ និងធ្វើការត្រួតពិនិត្យលើដំណើរការរបស់ ប.ស.ស.។ នៅក្នុងឆ្នាំ២០២៣ ក្រុមប្រឹក្សាភិបាលនៃ ប.ស.ស. បានបន្តរៀបចំកិច្ចប្រជុំអាណត្តិទី១ ឆ្នាំ២០២៣ របស់ខ្លួនបានចំនួន ៤លើក ជាលទ្ធផលសម្រេចបានដូចខាងក្រោម៖

- ពិនិត្យសម្រេចលើរបាយការណ៍លទ្ធផលការងារសម្រេចបានឆ្នាំ២០២២ និងទិសដៅអនុវត្តបន្តឆ្នាំ២០២៣ របស់បេឡាជាតិសន្តិសុខសង្គម
- សេចក្តីព្រាងសេចក្តីសម្រេចស្តីពីការកែសម្រួលបទបញ្ជាផ្ទៃក្នុងរបស់បេឡាជាតិសន្តិសុខសង្គម
- សេចក្តីព្រាងសេចក្តីសម្រេចស្តីពីការដាក់ឱ្យអនុវត្តគម្រោងសាកល្បងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់បុគ្គលស្វ័យនិយោជន៍
- សេចក្តីព្រាងប្រកាសស្តីពីលក្ខខណ្ឌបែបបទ និងនីតិវិធីនៃការផ្តល់ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់រយៈពេលសម្រាកព្យាបាលជំងឺ ប្រាក់បំណាច់មាតុភាព និងវិភាជន៍បូជាសព ក្នុងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពតាមរបបភាគទានជាកាតព្វកិច្ច
- សេចក្តីព្រាងអនុក្រឹត្យស្តីពីការដាក់ឱ្យអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពតាមរបបភាគទានដោយស្ម័គ្រចិត្ត
- សេចក្តីព្រាងប្រកាសស្តីពីលក្ខខណ្ឌបែបបទ និងនីតិវិធីនៃការផ្តល់វិភាជន៍បូជាសព ក្នុងរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ។

**ង.២. ក្រុមប្រឹក្សាធនាភិបាលសន្តិសុខសង្គម**

ក្រុមប្រឹក្សាធនាភិបាលសន្តិសុខសង្គមនៃ ប.ស.ស. ដែលមានតួនាទីក្នុងការគ្រប់គ្រងកិច្ចការវិនិយោគសន្តិសុខសង្គម ដែលបច្ចុប្បន្ននេះកំពុងស្ថិតនៅក្នុងសេចក្តីព្រាងអនុក្រឹត្យបង្កើតនៅឡើយ។

**ង.៣. ក្រុមប្រឹក្សាវេជ្ជសាស្ត្រនៃ ប.ស.ស.**

ក្នុងឆ្នាំ២០២៣ នេះ ក្រុមប្រឹក្សាវេជ្ជសាស្ត្រនៃ ប.ស.ស. បានរៀបចំកិច្ចប្រជុំចំនួន ២៧លើក ជាលទ្ធផលសម្រេចបានដូចខាងក្រោម៖

- ពិនិត្យ និងវាយតម្លៃលក្ខណសម្បត្តិរបស់មន្ទីរសម្រាកព្យាបាលមុន្នីរិទ្ធី និងមន្ទីរសម្រាកព្យាបាលព្រាបស ដែលបានស្នើសុំចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស.
- ពិនិត្យ និងវាយតម្លៃលក្ខណសម្បត្តិរបស់មន្ទីរសម្រាកព្យាបាលពន្លឺពេជ្រ និងមន្ទីរសម្រាកព្យាបាលសោភាបាគង ដែលបានស្នើសុំចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស.

- ពិនិត្យ និងវាយតម្លៃលក្ខណសម្បត្តិរបស់មន្ទីរពេទ្យ យី គក់ មន្ទីរសម្រាកព្យាបាលសំអាតដាលី និងមន្ទីរសម្រាកព្យាបាលពន្លឺអង្គរ ដែលបានស្នើសុំចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស.
- ពិនិត្យ និងវាយតម្លៃលក្ខណសម្បត្តិរបស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក កាមរោគ និងមន្ទីរសម្រាកព្យាបាលអរុណរះស្វាយរៀង ដែលបានស្នើសុំចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស.
- ពិនិត្យដោះស្រាយបញ្ហាប្រឈមក្នុងការអនុវត្តកិច្ចព្រមព្រៀង រវាងបេឡាជាតិសន្តិសុខសង្គម ជាមួយនឹងមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត
- ពិនិត្យ និងវាយតម្លៃលក្ខណសម្បត្តិរបស់មន្ទីរសម្រាកព្យាបាលរស្មីរួមមិត្ត ដែលបានស្នើសុំចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស.
- ពិនិត្យ និងផ្តល់យោបល់លើសេវាពិសេសបន្ថែមរបស់មន្ទីរពេទ្យមិត្តភាពកម្ពុជា-ចិនត្បូងឃ្មុំ
- ពិនិត្យ និងផ្តល់យោបល់លើសេវាពិសេសបន្ថែមរបស់មន្ទីរពេទ្យមិត្តភាពកម្ពុជា-ចិនត្បូងឃ្មុំ និងគ្លីនិកវ៉ាក់ ទាំង១០សាខា សាខាស្ទឹងមានជ័យ សាខាឫស្សីកែវ សាខាត្រពាំងថ្លឹង សាខាទឹកថ្លា សាខាចាក់អង្រែក្រោម សាខាកំពត សាខាក្រុងព្រះសីហនុ សាខាតាកែវ សាខាកំពង់ស្ពឺ និងសាខាកំពង់ចាម
- ពិនិត្យ និងសម្រេចលើមុខរបួសរបស់សមាជិក ឈ្មោះ ប៊ិត វ៉ា
- ពិនិត្យ និងផ្តល់យោបល់លើសេវាពិសេសបន្ថែម (Fee for service) របស់គ្លីនិកវ៉ាក់ទាំង១០សាខា (សាខាស្ទឹងមានជ័យ សាខាឫស្សីកែវ សាខាត្រពាំងថ្លឹង សាខាទឹកថ្លា សាខាចាក់អង្រែក្រោម សាខាកំពត សាខាក្រុងព្រះសីហនុ សាខាតាកែវ សាខាកំពង់ស្ពឺ និងសាខាកំពង់ចាម)
- ពិនិត្យ និងសម្រេចលើស្តង់ដាអប្បបរមាសម្រាប់មូលដ្ឋានសុខាភិបាលឯកជន ដែលត្រូវចុះកិច្ចព្រមព្រៀងជាមួយបេឡាជាតិសន្តិសុខសង្គម
- ពិនិត្យ និងផ្តល់យោបល់លើលក្ខណសម្បត្តិរបស់មន្ទីរពហុព្យាបាលមិត្តភាពកម្ពុជា-ចិនក្រុងបាវិត ដែលបានស្នើសុំតម្លើងកម្រិតពីកម្រិត១ (P1) ទៅកម្រិត៣ (P3)
- ពិនិត្យ និងផ្តល់យោបល់លើការស្នើសុំសេវាសម្រាកពេទ្យ (សំណើសុំអនុវត្តតម្លៃសេវាហិរញ្ញប្បទាន) របស់មណ្ឌលសុខភាពកោះកេរ្តិ៍
- ពិនិត្យ និងផ្តល់យោបល់លើឧបសម្ព័ន្ធទី២ នៃសេចក្តីព្រាងអនុក្រឹត្យស្តីពីយន្តការទូទាត់ថ្លៃសេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រ
- ពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងអនុក្រឹត្យស្តីពីយន្តការទូទាត់ថ្លៃសេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រ
- ពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងឧបសម្ព័ន្ធទី១ និងឧបសម្ព័ន្ធទី២ នៃប្រកាសអន្តរក្រសួងស្តីពីយន្តការទូទាត់ថ្លៃសេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រ
- ពិនិត្យ និងវាយតម្លៃលក្ខណសម្បត្តិរបស់មន្ទីរសម្រាកព្យាបាលស៊ីងស្តេសីលីស មេឌីខលសេនធ័រ ដែលបានស្នើសុំចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស.
- ពិនិត្យ និងផ្តល់យោបល់លើសេវា Body Corset (រុំស៊ីម៉ងត៍ខ្លួន) ដើម្បីទូទាត់សេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រផ្នែកហានិភ័យការងារជូនសមាជិក ប.ស.ស.

- ពិនិត្យ និងផ្តល់យោបល់លើសេវាសម្រាកព្យាបាលនៅមណ្ឌលសុខភាពម្លូព្រៃ និងមណ្ឌលសុខភាពផែប
- ពិនិត្យ និងវាយតម្លៃលក្ខណសម្បត្តិរបស់មន្ទីរពហុព្យាបាលពន្លឺបឹងធំ មន្ទីរសម្រាកព្យាបាលវីរៈសែនជ័យ មន្ទីរសម្រាកព្យាបាលនេសា និងមន្ទីរសម្រាកព្យាបាលមិត្តភាពអង្គធ្លកដែលបានស្នើសុំចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស.
- ពិនិត្យ និងវាយតម្លៃលក្ខណសម្បត្តិរបស់មន្ទីរសម្រាកព្យាបាលនេសា និងមន្ទីរសម្រាកព្យាបាលមិត្តភាពអង្គធ្លក (បន្តពីកិច្ចប្រជុំលើកទី៥៤) មន្ទីរសម្រាកព្យាបាលអរុណរះ២ មន្ទីរសម្រាកព្យាបាលអង្គរោង និងមន្ទីរសម្រាកព្យាបាលច្បារអំពៅ ដែលបានស្នើសុំចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស.
- បន្តពិនិត្យនិងវាយតម្លៃលក្ខណសម្បត្តិរបស់មន្ទីរសម្រាកព្យាបាលអរុណរះ២ មន្ទីរសម្រាកព្យាបាលច្បារអំពៅ និងមន្ទីរសម្រាកព្យាបាលអង្គរោងដែលបានស្នើសុំចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស.
- ពិនិត្យ និងវាយតម្លៃលក្ខណសម្បត្តិរបស់មន្ទីរសម្រាកព្យាបាលមុន្នីរិទ្ធី មន្ទីរសម្រាកព្យាបាលក្រុងកំពត ដែលបានស្នើសុំចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស.
- ពិនិត្យ និងវាយតម្លៃលក្ខណសម្បត្តិរបស់មន្ទីរសម្រាកព្យាបាលក្រុងកំពត (បន្តពីកិច្ចប្រជុំលើកមុន) និងមន្ទីរសម្រាកព្យាបាលស័ង្កម៉ារី ដែលបានស្នើសុំចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស.
- ពិនិត្យ និងវាយតម្លៃលក្ខណសម្បត្តិរបស់មន្ទីរសម្រាកព្យាបាលចោមចៅសិរីមង្គល និងមន្ទីរសម្រាកព្យាបាលពន្លឺបូព៌ា២ ដែលបានស្នើសុំចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស.
- ពិនិត្យ និងវាយតម្លៃលក្ខណសម្បត្តិរបស់មន្ទីរសម្រាកព្យាបាលសុខសាន្តគងពិសី និងមន្ទីរសម្រាកព្យាបាលស្រេងសេងហ៊ាង ដែលបានស្នើសុំចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស.
- ពិនិត្យ និងវាយតម្លៃលក្ខណសម្បត្តិរបស់មន្ទីរសម្រាកព្យាបាលផេង ហុល អូរចំណារ និងមន្ទីរសម្រាកព្យាបាលម៉ាណា ដែលបានស្នើសុំចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស.។

### ង.៤. គ្រូពេទ្យផ្លូវការនៃ ប.ស.ស.

ក្នុងឆ្នាំ២០២៣ នេះ គ្រូពេទ្យផ្លូវការនៃ ប.ស.ស. បានរៀបចំកិច្ចប្រជុំចំនួន ៥៩លើក ដើម្បីវាយតម្លៃការកាលិកបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ជូនសមាជិកចំនួន ១ ៤០៤នាក់ ស្រី ៥៧៧នាក់។

**តារាងទី៧៣៖ វាយតម្លៃកម្រិតបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍**

| បរិយាយ | ប្រជុំ (លើក) | កម្រិតតិចជាង ២០% | | កម្រិតចាប់ពី ២០% | | ជនរងគ្រោះសរុប | |
|---|---|---|---|---|---|---|---|
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ឆ្នាំ2022 | 31 | 148 | 51 | 779 | 295 | 927 | 346 |
| ឆ្នាំ2023 | 59 | 298 | 126 | 1,106 | 451 | 1,404 | 577 |
| បម្រែបម្រួល (±%) | 90.32% | 101.35% | 147.06% | 41.98% | 52.88% | 51.46% | 66.76% |

ប្រភព៖ នាយកដ្ឋានសេវាមូលដ្ឋានសុខាភិបាល

## ង.៥. ក្រុមការងារ

### ង.៥.១. ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត

ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិតបង្កើតឡើងតាមសេចក្តីសម្រេចលេខ០៨៩/២១ ក.ប/ស.ស.រ.ប.ស.ស ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២១។ នៅក្នុងឆ្នាំ២០២៣ នេះ ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត (ស.ផ.ក) បានរៀបចំកិច្ចប្រជុំផ្ទៃក្នុងចំនួន ១លើក ស្តីពីការពិនិត្យលើវីដេអូអប់រំខ្លីស្តីពីភ្លើងសញ្ញាចរាចរណ៍ និងវីដេអូមេរៀនការជែង ឬវ៉ា។

ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត បានចុះអង្កេតករណីកម្មករនិយោជិតមានគ្រោះថ្នាក់ចរាចរណ៍ និងជួយសង្គ្រោះបន្ទាន់បានចំនួន ១៦ករណី ក្នុងនោះមានកម្មករនិយោជិតទទួលរងគ្រោះថ្នាក់សរុប ៣៥១នាក់ ស្រី ២៩១នាក់។

**តារាងទី៧៤៖ បច្ចុប្បន្នភាពគ្រោះថ្នាក់ចរាចរណ៍របស់កម្មករនិយោជិត**

| គ្រោះថ្នាក់ចរាចរណ៍របស់កម្មករ | ករណី | ស្ថានភាពជនរងគ្រោះ (នាក់) | | | | | យានយន្តទូទៅ (%) | | | យានយន្តបង្កហេតុ (%) | | តាមវិស័យ (%) | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ស្លាប់ | ធ្ងន់ | ស្រាល | សរុប | ស្រី | ម៉ូតូ | រថយន្ត | ផ្សេងៗ | យានយន្តដឹកកម្មករ | យានយន្តដទៃ | រោងចក្រ | ធនាគារ/មីក្រូហិរញ្ញវត្ថុ | ផ្សេងៗ |
| ឆ្នាំ2022 | 4,805 | 152 | 1,498 | 3,984 | 5,634 | 3,287 | 94.00% | 2.00% | 4.00% | 38.00% | 62.00% | 59.00% | 8.00% | 33.00% |
| ឆ្នាំ2023 | 5,477 | 166 | 1,853 | 4,288 | 6,307 | 3,553 | 94.00% | 2.00% | 4.00% | 38.00% | 62.00% | 59.00% | 8.00% | 33.00% |
| បម្រែបម្រួល (± %) | 13.99% | 9.21% | 23.70% | 7.63% | 11.95% | 8.09% | 0.00% | 0.00% | 0.00% | 0.00% | 0.00% | 0.00% | 0.00% | 0.00% |

ប្រភព៖ នាយកដ្ឋានសេវាអតិថិជននិងទំនាក់ទំនងសាធារណៈ

### ង.៥.២. ក្រុមការងារទប់ស្កាត់ករណីសន្លប់ និងបង្ការគ្រោះថ្នាក់ការងាររបស់កម្មករនិយោជិតតាមសហគ្រាស គ្រឹះស្ថាន

ក្រុមការងារទប់ស្កាត់ករណីសន្លប់ និងបង្ការគ្រោះថ្នាក់ការងាររបស់កម្មករនិយោជិតតាមសហគ្រាសគ្រឹះស្ថានបង្កើតឡើងតាមសេចក្តីសម្រេចលេខ០០៥/១១ ក.ប/ស.ស.រ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១១។ នៅក្នុងឆ្នាំ២០២៣ នេះ ក្រុមការងារទប់ស្កាត់ករណីសន្លប់ និងបង្ការគ្រោះថ្នាក់ការងាររបស់កម្មករនិយោជិត (ទ.ស.ប.ក) បានរៀបចំកិច្ចប្រជុំផ្ទៃក្នុងចំនួន ១លើក ស្តីពីការពិនិត្យ និងកែសម្រួលលើសេចក្តីព្រាងសៀវភៅស្តីពីកម្រងមូលហេតុ និងវិធានការបង្ការករណីកម្មករនិយោជិតសន្លប់រយៈពេល ១០ឆ្នាំ និងសេចក្តីព្រាងកូនសៀវភៅស្តីពីមូលហេតុ និងវិធានការបង្ការករណីកម្មករនិយោជិតសន្លប់ បដាពាក្យស្លោក ខិត្តប័ណ្ណអប់រំស្តីពីលក្ខខណ្ឌអនាម័យ សុវត្ថិភាពការងារ លក្ខខណ្ឌការងារ និងបញ្ហាផ្សេងៗ។

ក្រុមការងារ ទ.ស.ប.ក បានចុះអង្កេតករណីកម្មករនិយោជិតសន្លប់ សម្របសម្រួលចាត់វិធានការកែលម្អ និងជួយសង្គ្រោះបន្ទាន់បានចំនួន ២រោងចក្រ និងមានកម្មករនិយោជិតសន្លប់សរុប ២៩នាក់ ស្រី ២៩នាក់។ ក្នុងនោះក្រុមការងារ ទ.ស.ប.ក សង្កេតឃើញថាមូលហេតុចម្បងៗ ដែលបណ្តាលឱ្យមានករណីកម្មករនិយោជិតសន្លប់ក្នុងចំណោមរោងចក្រទាំងពីរ គឺបណ្តាលមកពីបញ្ហាចិត្តសាស្ត្រសង្គមចំនួន ៥០% និងបញ្ហាជីវសាស្ត្រចំនួន ៥០%។

**តារាងទី៧៥៖ ទិន្នន័យរោងចក្រ និងកម្មកររោងចក្រដួលសន្លប់**

| បរិយាយ | រោងចក្រដែលមានករណីកម្មករនិយោជិតដួលសន្លប់ | | កម្មករនិយោជិតដួលសន្លប់ | |
|---|---|---|---|---|
| | រោងចក្រ | លើក | សរុប | ស្រី |
| ឆ្នាំ2022 | 11 | 11 | 304 | 259 |
| ឆ្នាំ2023 | 2 | 2 | 29 | 29 |
| បម្រែបម្រួល (± %) | -81.82% | -81.82% | -90.46% | -88.80% |

ប្រភព៖ នាយកដ្ឋានសេវាអតិថិជននិងទំនាក់ទំនងសាធារណៈ

### ង.៥.៣. ក្រុមការងារបច្ចេកទេសព័ត៌មានវិទ្យាសម្រាប់ធ្វើសុខដុមនីយកម្មប្រព័ន្ធចុះបញ្ជី និងគ្រប់គ្រងទិន្នន័យគាំពារសង្គម

ក្រុមការងារបច្ចេកទេសព័ត៌មានវិទ្យាបង្កើតឡើងតាមសេចក្តីប្រកាសអន្តរក្រសួងលេខ ១៣៦២ ប្រក ចុះថ្ងៃទី៧ ខែមេសា ឆ្នាំ២០១៤។ ក្រុមការងារនេះ មានតួនាទីភារកិច្ចរៀបចំនីតិវិធី បែបបទនៃការកំណត់អត្តសញ្ញាណកម្មករនិយោជិតដែលជាសមាជិក ប.ស.ស. ភ្ជាប់បណ្តាញព័ត៌មានវិទ្យារវាងនាយកដ្ឋានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ដើម្បីផ្តល់ និងធ្វើការផ្ទៀងផ្ទាត់ទិន្នន័យអត្តសញ្ញាណរបស់សមាជិក ប.ស.ស. ក្នុងរបបធានារ៉ាប់រងសុខភាព និងសហការជាមួយក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធ និងរោងចក្រសហគ្រាសដែលបានចុះបញ្ជិកាជាមួយ ប.ស.ស. សម្រាប់រៀបចំផែនការដើម្បីផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរអេឡិចត្រូនិចឱ្យបានត្រឹមត្រូវតាមនីតិវិធីជូនសមាជិក ប.ស.ស.។

ជាមួយគ្នានេះផងដែរក្រុមការងារបានរៀបចំផ្តល់អត្តសញ្ញាណប័ណ្ណថ្មី ទទួលពាក្យបណ្តឹងបាត់អត្តសញ្ញាណប័ណ្ណ អត្តសញ្ញាណប័ណ្ណរបកខូច អត្តសញ្ញាណប័ណ្ណកែតម្រូវ និងផ្តល់ឡើងវិញ (បន្តសុពលភាព) ជូនដល់សមាជិក ប.ស.ស. តាមរាជធានី ខេត្តបានចំនួន ២ ២៣៨នាក់ ស្រី ១ ១៥៥នាក់ តាមករណីដូចខាងក្រោម៖

**ក្រាហ្វិកទី១១. ចំនួនការផ្តល់អត្តសញ្ញាណប័ណ្ណតាមករណី**




ប្រភព៖ នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន

## ង.៦. ការងារផ្សព្វផ្សាយអប់រំ និងបង្ការ

### ង.៦.១. ពង្រឹងការផ្សព្វផ្សាយការអនុវត្តរបបសន្តិសុខសង្គម

ក្នុងឆ្នាំ២០២៣ ប.ស.ស. បានផ្សព្វផ្សាយការអនុវត្តរបបសន្តិសុខសង្គមសរុប ១ ៦២១លើក មានអ្នកចូលរួមចំនួន ៣២៦ ០៥២នាក់ ស្រី ២២០ ៩៧៩នាក់។ លើសពីនេះ ស្របតាមផែនការ ១០០ថ្ងៃ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងការចង្អុលបង្ហាញដ៏មុតស្រួចរបស់ **ឯកឧត្តមរដ្ឋមន្ត្រី** របបសន្តិសុខសង្គមផ្នែកថែទាំសុខភាពតាមរបបភាគទានដោយស្ម័គ្រចិត្តសម្រាប់បុគ្គលស្វ័យនិយោជន៍ និងអ្នកក្នុងបន្ទុកសមាជិក ប.ស.ស. ត្រូវបានប្រកាសដាក់ឱ្យអនុវត្ត ក្រោមអធិបតីភាព **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** នៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២៣ និង

បានប្រកាសបើកយុទ្ធនាការផ្សព្វផ្សាយរយៈពេល ៣០ថ្ងៃ តាមរោងចក្រ សហគ្រាស ផ្ទះជួល ផ្សារ និងទីប្រជុំជន ដោយសម្រេចបានចំនួន ៤ ៥៩៩លើក និងមានអ្នកចូលរួម ១ ៣៧១ ១២៩នាក់។

**តារាងទី៧៦៖ ផ្សព្វផ្សាយការអនុវត្តរបបសន្តិសុខសង្គម**

| សរុបការផ្សព្វផ្សាយការអនុវត្តរបបសន្តិសុខសង្គម | | | |
|---|---|---|---|
| បរិយាយ | លើក | អ្នកចូលរួម | |
| | | សរុប | ស្រី |
| ឆ្នាំ2022 | 3,985 | 1,136,096 | 754,302 |
| ឆ្នាំ2023 | 1,621 | 326,052 | 220,979 |
| បម្រែបម្រួល (± %) | -59.32% | -71.30% | -70.70% |
| ផ្សព្វផ្សាយផ្នែកហានិភ័យការងារ | | | |
| បរិយាយ | លើក | អ្នកចូលរួម | |
| | | សរុប | ស្រី |
| ឆ្នាំ2022 | 53 | 4,428 | 1,912 |
| ឆ្នាំ2023 | 197 | 17,736 | 11,673 |
| បម្រែបម្រួល (± %) | 271.70% | 300.54% | 510.51% |
| ផ្សព្វផ្សាយផ្នែកថែទាំសុខភាព | | | |
| បរិយាយ | លើក | អ្នកចូលរួម | |
| | | សរុប | ស្រី |
| ឆ្នាំ2022 | 50 | 4,232 | 1,847 |
| ឆ្នាំ2023 | 944 | 286,440 | 196,238 |
| បម្រែបម្រួល (± %) | 1,788.00% | 6,668.43% | 10,524.69% |
| ផ្សព្វផ្សាយផ្នែកប្រាក់សោធន | | | |
| បរិយាយ | លើក | អ្នកចូលរួម | |
| | | សរុប | ស្រី |
| ឆ្នាំ2022 | 3,882 | 1,127,436 | 750,543 |
| ឆ្នាំ2023 | 480 | 21,876 | 13,068 |
| បម្រែបម្រួល (± %) | -87.64% | -98.06% | -98.26% |

ប្រភព៖ នាយកដ្ឋានសេវាអតិថិជននិងទំនាក់ទំនងសាធារណៈ

សម្គាល់៖ ការផ្សព្វផ្សាយផ្នែកថែទាំសុខភាពតាមរបបភាគទានដោយស្ម័គ្រចិត្តចាប់ពីថ្ងៃទី១៥ វិច្ឆិកា ឆ្នាំ២០២៣ ដល់បំណាច់ខែវិច្ឆិកា ឆ្នាំ២០២៣។

### ង.៦.២. ការងារផ្សព្វផ្សាយរបស់ក្រុមការងារ ប.ស.ស. សហការជាមួយក្រុមការងារពង្រឹងការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យការងារ

ក្នុងឆ្នាំ២០២៣ ក្រុមការងារ ប.ស.ស. សហការជាមួយក្រុមការងារពង្រឹងការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យការងារបានចុះផ្សព្វផ្សាយអប់រំដល់សហគ្រាស គ្រឹះស្ថានចំនួន ៣៥លើក មានអ្នកចូលរួមសរុប ៦ ៨៦០នាក់ ស្រី ៦ ១៥៣នាក់។ ក្រុមការងារពង្រឹងការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យការងារបានបង្កើតឡើងតាមសេចក្ដីសម្រេចលេខ ២២ គកប ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៥។

### ង.៦.៣. ការងារផ្សព្វផ្សាយអប់រំអំពីលក្ខខណ្ឌអនាម័យ សុវត្ថិភាពការងារ លក្ខខណ្ឌការងារ និងអត្ថប្រយោជន៍របបសន្តិសុខសង្គម ជូនដល់កម្មករនិយោជិត

**តារាងទី៧៧៖ ការងារផ្សព្វផ្សាយអប់រំអំពីលក្ខខណ្ឌអនាម័យ សុវត្ថិភាពការងារ លក្ខខណ្ឌការងារ និងអត្ថប្រយោជន៍របបសន្តិសុខសង្គមជូនដល់កម្មករនិយោជិត**

| បរិយាយ | សហគ្រាសបានទទួលការផ្សព្វផ្សាយអប់រំ | | កម្មករនិយោជិតចូលរួម | |
|---|---|---|---|---|
| | សហគ្រាស | លើក | សរុប | ស្រី |
| ឆ្នាំ2022 | 7 | 7 | 431 | 379 |
| ឆ្នាំ2023 | 33 | 33 | 2,237 | 1,648 |
| បម្រែបម្រួល (± %) | 371.43% | 371.43% | 419.03% | 334.83% |

ប្រភព៖ នាយកដ្ឋានសេវាអតិថិជននិងទំនាក់ទំនងសាធារណៈ

### ង.៦.៤. ការងារផ្សព្វផ្សាយអប់រំច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកដល់កម្មករនិយោជិត និងអ្នកបើកបរ

**តារាងទី៧៨៖ ការងារផ្សព្វផ្សាយអប់រំច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកដល់កម្មករនិយោជិត និងអ្នកបើកបរ**

| បរិយាយ | កម្មករនិយោជិត | | | | អ្នកបើកបរយានយន្តដឹកកម្មករនិយោជិត | | | |
|---|---|---|---|---|---|---|---|---|
| | សហគ្រាស | លើក | អ្នកចូលរួម | ស្រី | សហគ្រាស | លើក | អ្នកចូលរួម | ស្រី |
| ឆ្នាំ2022 | 27 | 27 | 1,837 | 1,281 | 5 | 5 | 507 | 0 |
| ឆ្នាំ2023 | 128 | 128 | 24,204 | 20,366 | 34 | 34 | 2,315 | 0 |
| បម្រែបម្រួល (± %) | 374.07% | 374.07% | 1,217.58% | 1,489.85% | 580.00% | 580.00% | 356.61% | 0.00% |

ប្រភព៖ នាយកដ្ឋានសេវាអតិថិជននិងទំនាក់ទំនងសាធារណៈ

### ង.៦.៥. ការងារផ្សព្វផ្សាយតាមប្រព័ន្ធបណ្តាញសង្គម

**តារាងទី៧៩៖ ការងារផ្សព្វផ្សាយតាមប្រព័ន្ធបណ្តាញសង្គម**

| ល.រ | បរិយាយ | ចំនួនព័ត៌មាន |
|---|---|---|
| 1 | ផ្សព្វផ្សាយតាមរយៈ Facebook Page (បេឡាជាតិសន្តិសុខសង្គម ប.ស.ស.) | 344 |
| 2 | ផ្សព្វផ្សាយតាមរយៈគេហទំព័រ www.nssf.gov.kh | 132 |
| 3 | ផ្សព្វផ្សាយតាមរយៈ Youtube និង Telegram Channel (បេឡាជាតិសន្តិសុខសង្គម) | 297 |
| 4 | ការងារផ្សាយផ្ទាល់ (Live) លើ Facebook Page | 8 |
| សរុប | | 781 |

ប្រភព៖ នាយកដ្ឋានសេវាអតិថិជននិងទំនាក់ទំនងសាធារណៈ

## ង.៧. ការងារគាំទ្រទូទៅ

### ង.៧.១. ការងាររដ្ឋបាល និងហិរញ្ញវត្ថុ

❖ **ការងាររដ្ឋបាល**

ការងាររដ្ឋបាលមានតួនាទីយ៉ាងសំខាន់នៅក្នុងការគ្រប់គ្រងឯកសារ ការផ្គត់ផ្គង់ និងការគ្រប់គ្រងមន្ត្រី បុគ្គលិកដើម្បីធានាបាននូវការអនុវត្តបទបញ្ជាផ្ទៃក្នុងឱ្យមានប្រសិទ្ធភាព និងស្របតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា និងធានាបាននូវប្រសិទ្ធភាពការងារខ្ពស់។

❖ **ការងារថវិកា ហិរញ្ញវត្ថុ និងគណនេយ្យ**

ការងារថវិកា ហិរញ្ញវត្ថុ និងគណនេយ្យរបស់ ប.ស.ស. ប្រតិបត្តិការតាមរយៈប្រព័ន្ធធនាគារទាំងស្រុងពោលគឺរាល់កិច្ចដំណើរការនៃការគ្រប់គ្រងចំណូល និងចំណាយមានជាអាទិ៍ ការប្រមូលភាគទានពី

សហគ្រាស គ្រឹះស្ថានការបង់ប្រាក់ពិន័យ ការចំណាយតាវកាលិកដល់កម្មករនិយោជិតដែលរងហានិភ័យការងារ និងការចំណាយរដ្ឋបាលត្រូវបានប្រព្រឹត្តទៅដោយឆ្លងកាត់តាមប្រព័ន្ធធនាគារដៃគូក្នុងការប្រមូលភាគទាន បើកផ្តល់តាវកាលិក និងការរក្សាមូលនិធិបម្រុងសន្តិសុខសង្គមក្នុងគោលដៅធានាប្រសិទ្ធភាព និងគណនេយ្យភាព។ ដោយផ្អែកតាមការអនុវត្តក្នុងឆ្នាំ២០២៣ និងសក្ខីប័ត្រគណនេយ្យ បានឆ្លុះបញ្ចាំងនូវប្រភពចំណូលពីភាគទាន បានទទួលសម្រាប់របបសន្តិសុខសង្គម ផលហិរញ្ញវត្ថុឧបត្ថម្ភពីថ្នាក់ជាតិ ចំណូលពីប្រភពផ្សេងៗ ផលពីការផាកពិន័យផ្សេងៗ និងផលពីការគ្រប់គ្រងរដ្ឋបាលចំណាយតាវកាលិករបបសន្តិសុខសង្គម និងចំណាយប្រតិបត្តិការ។

### ង.៧.២. កិច្ចសហប្រតិបត្តិការ និងការងារបណ្តុះបណ្តាលធនធានមនុស្ស

កិច្ចសហប្រតិបត្តិការ និងការងារបណ្តុះបណ្តាលធនធានមនុស្សជាការងារមួយសំខាន់ ក្នុងការអភិវឌ្ឍអង្គភាព និងពង្រឹងនូវកិច្ចសហប្រតិបត្តិការរវាងផ្នែកដែលពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានាទាំងនៅក្នុងប្រទេស និងក្រៅប្រទេសដើម្បីធានានូវនិរន្តរភាពនៃកិច្ចដំណើរការរបស់អង្គភាព លើការរៀបចំផែនការ បែបបទ និងនីតិវិធីការងារក៏ដូចជាការអភិវឌ្ឍនូវចំណេះដឹង ការដកស្រង់ និងផ្លាស់ប្តូរបទពិសោធការងារថ្មីៗ។ កិច្ចសហប្រតិបត្តិការ និងការងារបណ្តុះបណ្តាលធនធានមនុស្ស ក៏ជាការចូលរួមចំណែកនៅក្នុងសកម្មភាពការងារសង្គមទាំងមូលឱ្យមានការរីកចម្រើនផងដែរ ដែលថ្នាក់ដឹកនាំក៏ដូចជាមន្ត្រី និងបុគ្គលិក ប.ស.ស. បានចូលរួមកិច្ចប្រជុំពិភាក្សាផ្តល់យោបល់ សិក្ខាសាលា វគ្គបណ្តុះបណ្តាល និងទស្សនកិច្ចសិក្សាទាំងនៅក្នុងប្រទេស និងក្រៅប្រទេសដូចខាងក្រោម៖

❖ **កិច្ចសហប្រតិបត្តិការ ប.ស.ស.**

**តារាងទី៨០៖ កិច្ចសហប្រតិបត្តិការ**

| បរិយាយ | លទ្ធផល |
|---|---|
| 1. កិច្ចសហប្រតិបត្តិការជាមួយអង្គការហ្គ្រេត (GRET) | |
| អនុស្សរណៈនៃការយោគយល់គ្នា (MOU) ស្តីពីគម្រោងកិច្ចគាំពារសង្គមផ្នែកនវានុវត្តន៍សម្រាប់វិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ (SPIN Project) | - ទទួលបានការឧបត្ថម្ភឧបករណ៍ និងសម្ភារផ្សេងៗបំពាក់ក្នុងបន្ទប់ផ្សព្វផ្សាយព័ត៌មានរបស់ ប.ស.ស.<br>- ទទួលបានវគ្គបណ្តុះបណ្តាលស្តីពីការប្រើប្រាស់ប្រព័ន្ធមជ្ឈមណ្ឌលព័ត៌មាននៃ ប.ស.ស. ជូនថ្នាក់ដឹកនាំ និងបុគ្គលិកនៃនាយកដ្ឋានសេវាអតិថិជននិងទំនាក់ទំនងសាធារណៈ និងនាយកដ្ឋានបញ្ជិកានិងភាគទាន<br>- បានសម្របសម្រួលកិច្ចប្រជុំ និងទស្សនកិច្ចជូនជំនាញការ នៃអង្គការហ្គ្រេត ដើម្បីសិក្សាឈ្វេងយល់អំពីប្រតិបត្តិការការងារ នៅសាខា ប.ស.ស. ខេត្តសៀមរាប នៃគម្រោង SPIN នៅថ្ងៃទី1-2 ខែកុម្ភៈ ឆ្នាំ2023<br>- រៀបចំ និងសម្របសម្រួលស្តីពីការវាយតម្លៃចុងក្រោយ នៃការអនុវត្តគម្រោង SPIN កាលពីថ្ងៃទី8 ខែកុម្ភៈ ឆ្នាំ2023 និងថ្ងៃទី16-17 ខែកុម្ភៈ ឆ្នាំ2023<br>- ទទួលបានសិក្ខាសាលាផ្សព្វផ្សាយស្តីពីលទ្ធផលនៃការសម្ភាសការវាយតម្លៃចុងក្រោយរបស់គម្រោង SPIN នៅថ្ងៃទី17 ខែមីនា ឆ្នាំ2023 នៅសណ្ឋាគារសាន់វេ<br>- ទទួលបានសិក្ខាសាលាផ្សព្វផ្សាយស្តីពីការដាក់ឱ្យអនុវត្ត គម្រោងសាកល្បងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់បុគ្គលស្វ័យនិយោជន៍ នៅសាលប្រជុំសន្តិភាព ប.ស.ស. នៅថ្ងៃទី27 ខែមីនា ឆ្នាំ2023<br>- ទទួលបានសិក្ខាសាលាបិទបញ្ចប់គម្រោងស្តីពីកិច្ចគាំពារសង្គមផ្នែកនវានុវត្តន៍សម្រាប់វិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ (SPIN Project) នៅសណ្ឋាគារ Poulo Wai Hotel and Apartment នៅថ្ងៃទី30 ខែមីនា ឆ្នាំ2023<br>- បន្តតាមដានទៅលើចំនួនអ្នកចុះឈ្មោះជាសមាជិក ប.ស.ស. នៅក្នុងគម្រោងសាកល្បង SPIN (អ្នកបើកត្រីចក្រយានយន្ត ចំនួនចុះបញ្ជិកាបាន 61% ស្មើនឹងចំនួន 1211នាក់ នៃចំនួនគោលដៅ 2 000នាក់) (សូមបញ្ជាក់គម្រោង SPIN នឹងបញ្ចប់ នៅចុងឆ្នាំ2023)។ |

| | |
|---|---|
| 2. អង្គភាពធានារ៉ាប់រងសុខភាពជាតិ (NHIS) នៃសាធារណរដ្ឋកូរ៉េ | |
| អនុស្សរណៈនៃការយោគយល់គ្នា (MOU) ស្តីពីការធានារ៉ាប់រងសុខភាពរវាងអង្គភាពធានារ៉ាប់រងសុខភាពជាតិ (NHIS) នៃសាធារណរដ្ឋកូរ៉េ និង ប.ស.ស. | ទទួលបានទស្សនកិច្ចសិក្សា នៅអង្គភាពធានារ៉ាប់រងសុខភាពជាតិ (NHIS) នៃសាធារណរដ្ឋកូរ៉េ។ |
| 3. កិច្ចសហប្រតិបត្តិការអាល្លឺម៉ង់ (GIZ) | |
| អនុស្សរណៈនៃការយោគយល់គ្នា (MOU) ស្តីពីគម្រោងសុវត្ថិកម្ម (ការធ្វើឱ្យប្រសើរឡើង) នៃប្រព័ន្ធកិច្ចគាំពារសង្គម និងសុខាភិបាល | - ទទួលបានការឧបត្ថម្ភថវិកាសម្រាប់ទស្សនកិច្ចសិក្សានៅអង្គភាពធានារ៉ាប់រងសុខភាពហ្វីលីពីន នៅប្រទេសហ្វីលីពីន នៅថ្ងៃទី15-19 ខែឧសភា ឆ្នាំ2023<br>- ទទួល Camera ថ្មី ជូននាយកដ្ឋានបញ្ជិកានិងភាគទានសម្រាប់ថតរូបសមាជិក ប.ស.ស. ពេលចុះបញ្ជិកា<br>- ទទួលកម្មវិធីអភិវឌ្ឍន៍ជំនាញទន់ ជូនថ្នាក់ដឹកនាំ និងបុគ្គលិកជំនាញ ប.ស.ស. ចំនួន 18លើក<br>- កិច្ចប្រជុំពិភាក្សាក្រុមការងារសម្រាប់កិច្ចសហប្រតិបត្តិការជាមួយអង្គការ GIZ និងតំណាង GIZ ស្តីពីគម្រោងវាយតម្លៃការយល់ដឹង និងការពេញចិត្តរបស់សមាជិក ប.ស.ស. ចំនួន 5លើក<br>- ក្រុមហ៊ុន Indochina Research (Cambodia) បានរៀបចំផែនការវិភាគភ្ជាប់មកជាមួយកម្រងសំណួរ និងរង់ចាំការឯកភាពពីតំណាង GIZ និងតំណាង ប.ស.ស. ដើម្បីក្រុមហ៊ុនដាក់ទៅគណៈកម្មាធិការជាតិក្រមសីលធម៌ សម្រាប់ការស្រាវជ្រាវសុខភាព (NECHR)<br>- នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានទទួលបានសម្ភារដោយផ្ទាល់ពីកិច្ចសហប្រតិបត្តិការអាល្លឺម៉ង់ (GIZ) ក្នុងការគាំទ្រលើគម្រោងស្តីពីការអភិវឌ្ឍប្រព័ន្ធចុះបញ្ជិកា និងបង់ភាគទានលើគេហទំព័រ (Web-Based Registration and Contribution Application)<br>- ទទួលការជួយឧបត្ថម្ភគាំទ្រជូនមន្ត្រីជំនាញ នៃនាយកដ្ឋានបញ្ជិកានិងភាគទាន ចំនួន 2រូប ដើម្បីចូលរួមកិច្ចប្រជុំស្តីពីបណ្តាញព័ត៌មានសុខភាពអេឡិចត្រូនិកអាស៊ីប្រចាំឆ្នាំ2023 (AeHIN General Meeting 2023) ក្រោមប្រធានបទការធានាសុខភាពឌីជីថលឱ្យកាន់តែមានលទ្ធផលល្អប្រសើរការរៀបចំផែនការក្នុងការអនុវត្ត (Ensuring Digital Health for Better Outcomes: Putting Blueprints into Practice) នៅទីក្រុងហ្សាការតា នៃសាធារណរដ្ឋឥណ្ឌូណេស៊ី ថ្ងៃទី6-9 ខែវិច្ឆិកា ឆ្នាំ2023<br>- កិច្ចប្រជុំពិភាក្សាក្រុមការងារសម្រាប់ត្រួតពិនិត្យកម្រងសំណួររបស់ក្រុមហ៊ុន Indochina Research (Cambodia) ក្នុងគម្រោងវាយតម្លៃការយល់ដឹង និងការពេញចិត្តរបស់សមាជិក ប.ស.ស. ថ្ងៃទី15 ខែវិច្ឆិកា ឆ្នាំ2023 នៅសាលនាយកដ្ឋានគោលនយោបាយសន្តិសុខសង្គម។ |
| 4. កិច្ចសហប្រតិបត្តិការរវាងអង្គការអន្តរជាតិខាងការងារ (ILO) | |
| គម្រោងស្តីពីលើការសិក្សា និងការវាយតម្លៃរបបធានារ៉ាប់រងសុខភាពនៃ ប.ស.ស. | - ចូលរួមកិច្ចប្រជុំ និងសិក្ខាសាលាផ្សព្វផ្សាយរបាយការណ៍ស្តីពីលទ្ធផលនៃការសិក្សា និងការវាយតម្លៃរបបថែទាំសុខភាពនៃ ប.ស.ស.<br>- ទទួលបានវគ្គបណ្តុះបណ្តាលស្តីពីការរៀបចំថវិការបបសន្តិសុខសង្គម ជូនថ្នាក់ដឹកនាំ នៃនាយកដ្ឋានគ្រប់គ្រងថវិកាហិរញ្ញវត្ថុនិងគណនេយ្យ នៅថ្ងៃទី1 ខែមីនា ដល់ថ្ងៃទី28 ខែមេសា ឆ្នាំ2023 នៅសណ្ឋាគារហ៊ីម៉ាវ៉ារី<br>- ទទួលបានវគ្គបណ្តុះបណ្តាលស្តីពីការត្រួតពិនិត្យតាមដានស្ថិតិ (Training on Monitoring Statistics) ជូនថ្នាក់ដឹកនាំនៃ ប.ស.ស. នៅថ្ងៃទី14-15 ខែមីនា ឆ្នាំ2023 នៅសណ្ឋាគារកាំបូឌីយ៉ាណា។ |
| ផែនការការងារស្តីពីការវាយតម្លៃហានិភ័យហិរញ្ញវត្ថុ និងការវិនិយោគ | - ផ្ញើនូវបច្ចុប្បន្នភាពទិន្នន័យ និងលិខិតបទដ្ឋានគតិយុត្តទៅជំនាញការរបស់អង្គការអន្តរជាតិខាងការងារ (ILO)<br>- សេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មការដឹកនាំក្រុមការងារបច្ចេកទេសសម្រាប់ការវាយតម្លៃហានិភ័យហិរញ្ញវត្ថុរបបសន្តិសុខសង្គម (គ.វ.ហ) របស់ ប.ស.ស.<br>- រៀបចំសំណើសុំចាត់ជនបង្គោលនៅនាយកដ្ឋានពាក់ព័ន្ធ ដើម្បីចូលរួមជាសមាជិកនៃក្រុមការងារបច្ចេកទេសសម្រាប់ការវាយតម្លៃហានិភ័យហិរញ្ញវត្ថុរបបសន្តិសុខសង្គម របស់ ប.ស.ស.<br>- ទទួលការជួយឧបត្ថម្ភគាំទ្រជូនមន្ត្រីជំនាញនៃនាយកដ្ឋានគ្រប់គ្រងថវិកាហិរញ្ញវត្ថុនិងគណនេយ្យ ចំនួន 3រូប ដើម្បីចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការវាយតម្លៃហានិភ័យហិរញ្ញវត្ថុសម្រាប់ប្រព័ន្ធសន្តិសុខសង្គមក្នុងតំបន់នៅទីក្រុងបាងកក នៃព្រះរាជាណាចក្រថៃឡង់ដ៍ ថ្ងៃទី20-24 ខែវិច្ឆិកា ឆ្នាំ 2023<br>- ថ្ងៃទី15 ខែធ្នូ ឆ្នាំ2023 កិច្ចប្រជុំស្តីពីកាវាយតម្លៃហានិភ័យហិរញ្ញវត្ថុនៃ ប.ស.ស. នៅសាលប្រជុំនាយកដ្ឋានសេវាអតិថិជននិងទំនាក់ទំនងសាធារណៈ។ |

| | |
|---|---|
| គម្រោងជំនួយលើយុទ្ធសាស្ត្រផ្សព្វផ្សាយរបស់ ប.ស.ស. | - ប្រជុំពិភាក្សាស្តីពីយុទ្ធសាស្ត្រផ្សព្វផ្សាយរបស់ ប.ស.ស. ទទួលបានលទ្ធផលៈ<br>• អង្គការ ILO គ្រោងនឹងចុះកិច្ចព្រមព្រៀងអនុវត្តន៍ (IA) ស្តីពីការអនុវត្តយុទ្ធសាស្ត្រផ្សព្វផ្សាយជាមួយ ប.ស.ស. បន្ទាប់ពីអង្គការ ILO ពិនិត្យលើផែនការសកម្មភាពរយៈពេលខ្លី (3ខែ)<br>• អង្គការ ILO ស្នើសុំឱ្យ ប.ស.ស. ធ្វើសូចនាករដើម្បីកំណត់ថា តើ ប.ស.ស. ចង់សម្រេចបានអ្វីខ្លះសម្រាប់ផែនការសកម្មភាព រយៈពេលខ្លី (3ខែ)។<br>- ទទួលឯកសារស្តីពីយុទ្ធសាស្ត្រ និងផែនការផ្សព្វផ្សាយរយៈពេល5ឆ្នាំ របស់ ប.ស.ស. (NSSF Communication Strategy and Action Plan) (ដំណាក់កាលទី1)<br>- កិច្ចប្រជុំពិភាក្សាយុទ្ធសាស្ត្រផ្សព្វផ្សាយរបស់ ប.ស.ស. ស្តីពីសេចក្តីព្រាងចុះកិច្ចព្រមព្រៀងអនុវត្តន៍ (IA) មានរយៈពេល 1ឆ្នាំ (ដំណាក់កាលទី2)<br>- ប្រមូលធាតុចូល និងរៀបចំសេចក្តីព្រាងនៃកិច្ចព្រមព្រាង ការអនុវត្តសម្រាប់ការគាំទ្រដល់ការបង្កើនសមាជិកភាពរបស់ ប.ស.ស.<br>- ផ្ញើ Email ទៅអង្គការអន្តរជាតិខាងការងារ (ILO) ស្តីពីកិច្ចព្រមព្រៀងការអនុវត្តសម្រាប់ការគាំទ្រដល់ការបង្កើនសមាជិកភាពរបស់ ប.ស.ស. (IA) ដើម្បីពិនិត្យ។ |
| គម្រោងទំនើបភាវូបនីយកម្មរបស់ ប.ស.ស. | - កិច្ចប្រជុំពិភាក្សាការវាយតម្លៃនៃគម្រោងស្តីពីទំនើបភាវូបនីយកម្មនៃ ប.ស.ស. ដំណាក់កាលទី2 ថ្ងៃទី16 ខែវិច្ឆិកា ឆ្នាំ2023 តាមប្រព័ន្ធអនឡាញ បានពិនិត្យលើកម្រងសំណួរ និងដាក់ជូននាយកដ្ឋានជំនាញដើម្បីបំពេញ<br>- ថ្ងៃទី14 ខែធ្នូ ឆ្នាំ2023 នៅសាលប្រជុំសេវាអតិថិជននិងទំនាក់ទំនងសាធារណៈ ស្តីពីកិច្ចប្រជុំការវាយតម្លៃទំនើបភាវូបនីយកម្ម ប.ស.ស. ដំណាក់កាលទី2។ |
| **5.កិច្ចសហប្រតិបត្តិការជាមួយអង្គភាពសោធនជាតិ (NPS)** | |
| អនុស្សរណៈនៃការយោគយល់គ្នា (MOU) ស្តីពីកិច្ចសហ-ប្រតិបត្តិការគ្នាទៅវិញទៅមក | - ចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នារវាង ប.ស.ស. និងអង្គភាពសោធនជាតិនៃសាធារណរដ្ឋកូរ៉េ ស្តីពីកិច្ចសហប្រតិបត្តិការគ្នាទៅវិញទៅមក នៅថ្ងៃទី28 ខែកុម្ភៈ ឆ្នាំ2023 នៅសាលប្រជុំករុណានៃ ប.ស.ស.<br>- ទទួលបានវគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនរបស់អង្គភាពសោធនជាតិកូរ៉េ (NPS) ជូនថ្នាក់ដឹកនាំ មន្ត្រី និងបុគ្គលិកនៃ ប.ស.ស. នៅថ្ងៃទី1-2 ខែមីនា ឆ្នាំ2023 នៅសាលប្រជុំករុណានៃ ប.ស.ស.<br>- ទទួលបានវគ្គបណ្តុះបណ្តាលប្រចាំឆ្នាំ លើកទី១ ស្តីពីរបបផ្នែកប្រាក់សោធនសាធារណៈ នៅទីក្រុងសេអ៊ូល និងទីក្រុងជិនជូ នៃសាធារណរដ្ឋកូរ៉េនៅថ្ងៃទី23-26 ខែឧសភា ឆ្នាំ2023។ |
| **6.កិច្ចសហប្រតិបត្តិការជាមួយអង្គភាពធានារ៉ាប់រងសុខភាពហ្វីលីពីន (PhilHealth)** | |
| អនុស្សរណៈនៃការយោគយល់គ្នា (MOU) ស្តីពីភាពជាដៃគូ និងចែករំលែកសម្រាប់ ការអភិវឌ្ឍវិស័យធានារ៉ាប់រងសន្តិសុខសង្គម | ទទួលបានទស្សនកិច្ចសិក្សានៅអង្គភាពធានារ៉ាប់រងសុខភាពហ្វីលីពីននៅប្រទេសហ្វីលីពីន។ |
| **7. អង្គភាពសុខុមាលភាព និងសំណងគ្រោះថ្នាក់ការងារ (COMWEL) នៃសាធារណរដ្ឋកូរ៉េ** | |
| គម្រោងជំនួយអភិវឌ្ឍន៍ផ្លូវការសម្រាប់ស្តារនីតិសម្បទាសម្រាប់កម្មករនិយោជិតដែលទទួលរងគ្រោះថ្នាក់ការងារនៅកម្ពុជា | - ទទួលបានរបាយការណ៍ឆ្នាំទី1 ស្តីពីការអនុវត្តគម្រោងជំនួយអភិវឌ្ឍន៍ផ្លូវការផ្នែកស្តារនីតិសម្បទានៅកម្ពុជាពីអង្គភាពសុខុមាលភាព និងសំណងគ្រោះថ្នាក់ការងារ (COMWEL) នៃសាធារណរដ្ឋកូរ៉េ<br>- ដំណើរទស្សនកិច្ចសិក្សានៅប្រទេសថៃ ស្តីពីសេវាស្តារនីតិសម្បទាដើម្បីប្រមូលធាតុចូលដែលជាផ្នែកមួយសម្រាប់កសាងផែនការមេផ្នែកស្តារនីតិសម្បទានៅកម្ពុជា នៃគម្រោងជំនួយអភិវឌ្ឍន៍ផ្លូវការ<br>- ផ្ញើកម្រងសំណួរបន្ថែមរបស់មន្ត្រីជំនាញនៃនាយកដ្ឋានស្តារនីតិសម្បទា ក្នុងអំឡុងពេលដំណើរទស្សនកិច្ច កាលពីថ្ងៃទី17-22 ខែកញ្ញា ឆ្នាំ2023 ទៅអង្គភាពសុខុមាលភាព និងសំណងគ្រោះថ្នាក់ការងារ (COMWEL)<br>- បានសហការជាមួយនាយកដ្ឋានជំនាញពាក់ព័ន្ធដើម្បីប្រមូលទិន្នន័យផ្តល់ជូនអង្គភាព (COMWEL) សម្រាប់គម្រោងជំនួយអភិវឌ្ឍន៍ផ្លូវការក្នុងការកសាងផែនការមេផ្នែកស្តារនីតិសម្បទារយៈពេល 5ឆ្នាំរបស់ ប.ស.ស. និងសម្រាប់រៀបចំគម្រោងថ្មីក្នុងការកសាងមជ្ឈមណ្ឌលផ្តល់សេវាស្តារនីតិសម្បទាសម្រាប់ពិគ្រោះជំងឺក្រៅរបស់ ប.ស.ស.<br>- ថ្ងៃទី4-8 ខែធ្នូ ឆ្នាំ2023 បានសម្របសម្រួលដំណើរទស្សនកិច្ចសិក្សាស្តីពីការសិក្សាសមិទ្ធិលទ្ធភាពនៃគម្រោងជំនួយអភិវឌ្ឍន៍ផ្លូវការសម្រាប់ការកសាងមជ្ឈមណ្ឌលស្តារនីតិសម្បទាសម្រាប់សមាជិក ប.ស.ស. នៅកម្ពុជា។ |

ប្រភពៈ នាយកដ្ឋានសេវាអតិថិជននិងទំនាក់ទំនងសាធារណៈ

❖ ការងារបណ្តុះបណ្តាលធនធានមនុស្ស

**តារាងទី៨១៖ ការងារបណ្តុះបណ្តាលធនធានមនុស្ស**

| ល.រ | បរិយាយ | ឆ្នាំ2022 | | | ឆ្នាំ2023 | | | បម្រែបម្រួល (± %) | | |
|---|---|---|---|---|---|---|---|---|---|---|
| | | វគ្គ | សរុប | ស្រី | វគ្គ | សរុប | ស្រី | វគ្គ | សរុប | ស្រី |
| | | | នាក់ | | | នាក់ | | | | |
| 1. ការចូលរួមវគ្គបណ្តុះបណ្តាល និងសិក្ខាសាលា | | 45 | 772 | 281 | 76 | 1,836 | 764 | 68.89% | 137.82% | 171.89% |
| 1.1 | ក្នុងប្រទេស | 42 | 757 | 276 | 62 | 1,794 | 748 | 47.62% | 136.99% | 171.01% |
| 1.2 | ក្រៅប្រទេស | 3 | 15 | 5 | 14 | 42 | 16 | 366.67% | 180.00% | 220.00% |
| 2. ការចូលរួមទស្សនកិច្ចសិក្សា | | 0 | 0 | 0 | 4 | 21 | 4 | 100.00% | 100.00% | 100.00% |
| 2.1 | ក្នុងប្រទេស | 0 | 0 | 0 | 0 | 0 | 0 | 0.00% | 0.00% | 0.00% |
| 2.2 | ក្រៅប្រទេស | 0 | 0 | 0 | 4 | 21 | 4 | 100.00% | 100.00% | 100.00% |
| សរុប (1+2) | | 45 | 772 | 281 | 80 | 1,857 | 768 | 77.78% | 140.54% | 173.31% |

ប្រភព៖ នាយកដ្ឋានរដ្ឋបាលនិងគ្រប់គ្រងធនធានមនុស្ស

### ង.៧.៣. ការងារព័ត៌មានវិទ្យា

ប.ស.ស. បានរៀបចំកិច្ចប្រតិបត្តិការការងារ និងការគ្រប់គ្រងប្រព័ន្ធទិន្នន័យសហគ្រាស គ្រឹះស្ថានសមាជិកចុះបញ្ជិកា បង់ភាគទាន ការផ្តល់តាវកាលិក ប្រព័ន្ធគ្រប់គ្រងការងាររដ្ឋបាល និងប្រព័ន្ធគ្រប់គ្រងការងារសំខាន់ៗមួយចំនួនទៀតតាមរយៈបច្ចេកវិទ្យាព័ត៌មានវិទ្យាជាក់ស្តែង នៅក្នុងឆ្នាំ២០២៣ នេះ ប.ស.ស. សម្រេចបានលើការងារព័ត៌មានវិទ្យាដូចខាងក្រោម៖

- កម្មវិធី Sage និង HSPIS
- កម្មវិធីស្កេនឯកសារតាមការិយាល័យ
- កម្មវិធីបញ្ជិកានិងភាគទាន រដ្ឋបាលគ្រប់គ្រងរបបប្រាក់សោធន គ្រប់គ្រងបេសកកម្ម បោះពុម្ពកាតសមាជិក ប.ស.ស. និងការចុះបញ្ជិកាអ្នករត់ម៉ូតូកង់បី និងអ្នកធ្វើការតាមផ្ទះ
- កម្មវិធី E-Form សម្រាប់សោធននិវត្តន៍
- កម្មវិធីប្រព័ន្ធគ្រប់គ្រងគណនីប្រើប្រាស់សម្រាប់ផ្ញើឈ្មោះសហគ្រាសទៅធនាគារ និងសម្រាប់បង់ភាគទានបុគ្គលស្វ័យនិយោជន៍
- កម្មវិធី NSSF Member ថ្មី
- កម្មវិធីប្រាក់ឧបត្ថម្ភសម្រាប់ស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ
- កម្មវិធីចុះឈ្មោះបេក្ខជនប្រលងតាម Online
- កម្មវិធី Agent App Member និង Nssf Staff Mobile App
- កម្មវិធីស្វែងរកសហគ្រាស
- កម្មវិធីរបាយការណ៍ប្រតិបត្តិការរបស់ ប.ស.ស.
- កម្មវិធីតាវកាលិកថ្មី (New NSSF Benefit)
- កម្មវិធី API បញ្ជិកា និងភាគទាន សម្រាប់គេហទំព័រ ប.ស.ស. សម្រាប់ទាញទិន្នន័យពីប្រព័ន្ធចុះបញ្ជិកាថ្មីមកប្រព័ន្ធចាស់ សម្រាប់បង់ភាគទានបុគ្គលស្វ័យនិយោជន៍ Claim Agent និង App Member App

- គេហទំព័រ ប.ស.ស.

- គ្រប់គ្រង Web Hosting និងមូលដ្ឋានទិន្នន័យ Database

- ប្រព័ន្ធចុះបញ្ជិកា និងភាគទានថ្មី គ្រប់គ្រងស្តុករដ្ឋបាល គ្រប់គ្រងឯកសារ និងគ្រប់គ្រងបណ្តឹង។

**ង.៧.៤. ការងារសវនកម្មផ្ទៃក្នុង**

ពង្រឹងការអនុវត្តមុខងារសវនកម្មផ្ទៃក្នុង ចុះធ្វើសវនកម្មនៅនាយកដ្ឋានស្នាក់ការកណ្តាល និងសាខា ប.ស.ស. ខេត្ត ក្រុង ស្រុក ខណ្ឌ។

## ៣. បញ្ហាប្រឈមចម្បងៗ

- របបសន្តិសុខសង្គមផ្នែកប្រាក់សោធនរបស់មន្ត្រីសាធារណៈ មិនទាន់ត្រូវបានរៀបចំឱ្យមកនៅក្រោមសមត្ថកិច្ច ប.ស.ស.
- បញ្ហាសុខភាព និងករណីគ្រោះថ្នាក់ចរាចរណ៍នៅតែបន្តកើតមានដោយសារបញ្ហាបទដ្ឋានបច្ចេកទេស និងស្តង់ដានៃមធ្យោបាយដឹកជញ្ជូនកម្មករនិយោជិត
- ការមិនយល់ពីសារៈសំខាន់នៃអត្រានុកូលដ្ឋានធ្វើឱ្យមានផលលំបាកក្នុងការចុះបញ្ជីអ្នកនៅក្នុងបន្ទុកសមាជិក ប.ស.ស. ដែលរួមមានដូចជា៖ សំបុត្រអាពាហ៍ពិពាហ៍ សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ
- ការយល់ដឹងនៅមានកម្រិតអំពីសារៈសំខាន់នៃរបបសន្តិសុខសង្គម ក្នុងការធានាការពារដល់សន្តិសុខ និងស្ថិរភាពប្រាក់ចំណូល ចំពោះហានិភ័យសំខាន់ៗ ពីសំណាក់កម្មករនិយោជិត ក៏ដូចជាអំពីតួនាទីរបបសន្តិសុខសង្គមក្នុងការចូលរួមចំណែកលើកកម្ពស់ផលិតភាពពីសំណាក់និយោជក
- ការយល់ដឹងពីកាតព្វកិច្ច និងអត្ថប្រយោជន៍របបសន្តិសុខសង្គមនៅមានកម្រិតជាហេតុធ្វើឱ្យការគ្របដណ្តប់របបសន្តិសុខសង្គមមិនទាន់បានទូលំទូលាយ
- បុគ្គលស្វ័យនិយោជន៍មួយចំនួនមិនមានពេលវេលាគ្រប់គ្រាន់ដើម្បីទៅធ្វើប័ណ្ណសមាជិក ប.ស.ស. (ភាគច្រើនជាអាជីវករលក់ដូរតាមផ្សារ)
- វិស័យក្រៅប្រព័ន្ធ និងសហគ្រាសធុនមីក្រូ តូច និងមធ្យម នៅមានអត្រាខ្ពស់ ដែលនាំឱ្យការពង្រីកវិសាលភាពគ្របដណ្តប់ពេញលេញនៃរបបសន្តិសុខសង្គមដែលឈរលើការបង់ភាគទានជាកាតព្វកិច្ចនៅមានកម្រិត
- ប្រព័ន្ធគ្រប់គ្រងទិន្នន័យកម្មករនិយោជិត និងសហគ្រាស គ្រឹះស្ថាន នៅមិនទាន់តភ្ជាប់ជាមួយមូលដ្ឋានទិន្នន័យក្នុងប្រព័ន្ធរួមតែមួយរបស់ក្រសួង ដើម្បីផ្តល់ភាពងាយស្រួល និងប្រសិទ្ធភាពក្នុងការគ្រប់គ្រង និងតាមដានការចុះបញ្ជិកា និងបង់ភាគទានព្រមទាំងការបើកផ្តល់តាវកាលិក និងអត្ថប្រយោជន៍
- អត្រាប្រាក់ឈ្នួលមធ្យមរបស់កម្មករនិយោជិតភាគច្រើន នៅមានកម្រិត ដែលនាំឱ្យលទ្ធភាពនៃការបង់ភាគទានរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់សមាជិកគ្រួសារនៅមានកម្រិត
- សមត្ថភាពនៃការផ្តល់សេវារបស់មូលដ្ឋានសុខាភិបាលដៃគូមួយចំនួននៅមានកម្រិត
- ពលករទេសន្តរប្រវេសន៍ដែលធ្វើមាតុភូមិនិវត្តន៍ អាចប្រឈមនឹងការបាត់បង់អត្ថប្រយោជន៍ពីរបបសន្តិសុខសង្គមដែលខ្លួនបានបង់ភាគទាននៅប្រទេសដែលខ្លួនបានទៅធ្វើការ ដោយសារមិនទាន់មានក្របខ័ណ្ឌផ្លូវការនៃការធ្វើចល័តភាពរបបសន្តិសុខសង្គម។

## ៤. ទិសដៅអនុវត្តបន្ត

- រៀបចំ និងកែសម្រួលលិខិតបទដ្ឋានគតិយុត្តសម្រាប់អភិវឌ្ឍន៍របបសន្តិសុខសង្គម ដូចជាការកំណត់ប្រភេទជំងឺវិជ្ជាជីវៈ កំណត់ឯកតាចំណាយនៃកញ្ចប់តាវកាលិកឱ្យស្របតាមស្ថានភាពនៃទីផ្សារសុខភាព -ល-
- ពង្រឹងការផ្តល់សេវាស្តារនីតិសម្បទាតាមរយៈការសហការជាមួយភាគីពាក់ព័ន្ធ ជាពិសេស អគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ និងអង្គភាពផ្តល់សេវាការងារសាធារណៈ
- ពង្រឹង និងបង្កើនការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន ដើម្បីធានាការគ្របដណ្តប់ការអនុវត្តរបបសន្តិសុខសង្គមដល់កម្មករនិយោជិតដែលកំពុងបម្រើការងារនៅតាមសហគ្រាស គ្រឹះស្ថាន
- ពង្រឹងការអនុវត្តច្បាប់ និងចាត់វិធានការយ៉ាងម៉ឺងម៉ាត់ចំពោះសហគ្រាស គ្រឹះស្ថានណាដែលមិនអនុលោមតាមច្បាប់ ប.ស.ស.
- សិក្សារៀបចំ និងបង្កើតក្រុមការងារសម្របសម្រួលចុះបញ្ជីចល័តភាពទីប្រជុំជន និងផ្សារ
- ពិនិត្យលទ្ធភាពកែសម្រួលបែបបទ និងនីតិវិធីនៃការចុះបញ្ជី ពិសេសជំរុញការអនុវត្តតាមប្រព័ន្ធថ្នាលបច្ចេកវិទ្យា
- ជំរុញការចរចាចល័តភាពរបបសន្តិសុខសង្គមជាមួយបណ្តាប្រទេសទទួលពលករកម្ពុជា ពិសេសប្រទេសថៃ
- សិក្សាសមិទ្ធិលទ្ធភាពរៀបចំ និងដាក់ឱ្យដំណើរការរបបសន្តិសុខសង្គមផ្នែកនិកម្មភាពការងារ
- បន្តពង្រឹង និងបង្កើនគុណភាព ប្រសិទ្ធភាពនៃការផ្តល់សេវាមូលដ្ឋានសុខាភិបាលជាដៃគូ
- ពង្រឹង និងបន្តការបើកតាវកាលិករបបសន្តិសុខសង្គម និងប្រាក់ឧបត្ថម្ភរាជរដ្ឋាភិបាលសម្រាប់សមាជិក ប.ស.ស. ដែលជាស្ត្រីមានផ្ទៃពោះ និងកូនអាយុក្រោម ២ឆ្នាំ
- ពង្រឹងការផ្តល់សេវាស្តារនីតិសម្បទាផ្នែកវេជ្ជសាស្ត្រ ផ្នែកបណ្តុះបណ្តាលវិជ្ជាជីវៈ ផ្នែកសេវាសង្គម និងសេវាសម្របសម្រួលរកការងារ
- បន្តជំរុញការផ្សព្វផ្សាយអំពីអត្ថប្រយោជន៍របបសន្តិសុខសង្គមគ្រប់រូបភាព និងគ្រប់ទម្រង់ប្រកបដោយភាពប្រទាក់ក្រឡាគ្នា
- សិក្សា ជំរុញការកែសម្រួលមធ្យោបាយដឹកជញ្ជូនកម្មករនិយោជិតតាមរយៈការស្វែងរកយន្តការគ្រប់គ្រងដោយក្រុមហ៊ុន ឬអង្គភាពមួយណាច្បាស់លាស់
- សហការរៀបចំវិនិយោគលើអគារ និងហេដ្ឋារចនាសម្ព័ន្ធ ទារកដ្ឋាន និងមត្តេយ្យសហគមន៍នូវតំបន់ដែលមានបណ្តុំកម្មករនិយោជិត ដើម្បីបង្កើនឱកាសការងារ និងលើកកម្ពស់សុខភាពមាតា និងទារក ព្រមទាំងចូលរួមលើកកម្ពស់ការអនុវត្តគោលនយោបាយជាតិស្តីពីកិច្ចការពារកុមារ
- ជំរុញការរៀបចំបរិវត្តកម្មបច្ចេកវិទ្យាទាំងស្រុង និងគ្រប់ជ្រុងជ្រោយនៃប្រតិបត្តិការប្រចាំថ្ងៃសំដៅធានាប្រសិទ្ធភាព និងប្រសិទ្ធផលនៃការផ្តល់សេវា។

## ៥. សេចក្តីសន្និដ្ឋាន

តាមរយៈការចុះបញ្ជិកា ការបង់ភាគទាន ការបើកផ្តល់តាវកាលិក ការបង្ការហានិភ័យការងារ និងការគាំទ្រផ្សេងៗ បានបង្ហាញឱ្យឃើញពីលទ្ធផលដ៏ល្អ ដែលបានឆ្លុះបញ្ចាំងឱ្យឃើញយ៉ាងច្បាស់ថា ប.ស.ស. បាននឹងកំពុងបោះជំហានទៅមុខមួយកម្រិតទៀត បន្ទាប់ពីការអនុវត្តយ៉ាងជោគជ័យនូវរបបសន្តិសុខសង្គម

ផ្នែកហានិភ័យការងារ ផ្នែកថែទាំសុខភាព និងផ្នែកប្រាក់សោធន។ នៅក្នុងឆ្នាំ២០២៣ នេះ ប.ស.ស. ដាក់ឱ្យអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពតាមរបបភាគទានដោយស្ម័គ្រចិត្ត សម្រាប់បុគ្គលស្វ័យនិយោជន៍ និងការដាក់ឱ្យអនុវត្តនូវគោលការណ៍ផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ ប្រកបដោយជោគជ័យ ដែលទទួលបានការគាំទ្រយ៉ាងខ្លាំងពីថ្នាក់ជាតិ និងអន្តរជាតិ។ ការអនុវត្តរបបសន្តិសុខសង្គមរបស់ ប.ស.ស. គឺមានគោលបំណងដើម្បីធានាសមធម៌និងសាមគ្គីធម៌សង្គម និងដើម្បីលើកកម្ពស់សុខុមាលភាព និងជីវភាពរបស់ប្រជាពលរដ្ឋ ពិសេសសមាជិករបស់ខ្លួនក្នុងការផ្តល់សេវាប្រកបដោយប្រសិទ្ធភាព និរន្តរភាព និងប្រកបដោយបរិយាបន្ននិងសង្គតិភាព។ ការណ៍នេះឆ្លុះបញ្ចាំងឱ្យឃើញពីការយកចិត្តទុកដាក់ពីប្រមុខរាជរដ្ឋាភិបាល និងកិច្ចខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំ មន្ត្រី និងបុគ្គលិក ប.ស.ស. ទាំងអស់។

ទន្ទឹមនឹងលទ្ធផលការងារខាងលើ ប.ស.ស. បានសង្កេតឃើញបញ្ហាប្រឈមចម្បងៗមួយចំនួនទាក់ទងនឹងការអនុវត្តកាតព្វកិច្ចមិនទាន់បានល្អប្រសើរពីសំណាក់និយោជក និងកម្មករនិយោជិតមួយចំនួនតូច ការផ្តល់សេវារបស់មូលដ្ឋានសុខាភិបាល និងបញ្ហារបស់ ប.ស.ស. មួយចំនួនផងដែរត្រូវបានកែលម្អជាបន្តបន្ទាប់។ ផ្សារភ្ជាប់ទៅនឹងបញ្ហាដូចដែលបានលើកឡើងខាងលើនេះដែរ ប.ស.ស. ក៏បានកត់សម្គាល់ឃើញថាក្នុងឆ្នាំ២០២៣ ការប្រើប្រាស់សេវាថែទាំសុខភាពនៅតែកើតមានឡើង ដូចនេះដើម្បីចូលរួមដោះស្រាយបញ្ហាខាងលើឱ្យបានកាន់តែល្អប្រសើរ ទាមទារឱ្យមានការបន្តជួយជ្រោមជ្រែង គាំទ្រសហការបន្ថែមទៀតពីសំណាក់ក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការជាតិ អន្តរជាតិ និងដៃគូអភិវឌ្ឍន៍នានា នៅក្នុងការអភិវឌ្ឍវិស័យសន្តិសុខសង្គមនៅកម្ពុជាឱ្យមានការរីកចម្រើន និងសូមឱ្យមានការចូលរួមយ៉ាងសកម្មក្នុងការចាត់វិធានការផ្សព្វផ្សាយអប់រំដើម្បីបង្ការ និងទប់ស្កាត់គ្រោះថ្នាក់ការងារឱ្យនៅកម្រិតទាបបំផុត និងលក្ខខណ្ឌអនាម័យល្អដែលជាផ្នែកមួយចូលរួមចំណែកកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់ស្ថិរភាពសង្គម។ ម៉្យាងវិញទៀតកម្មករនិយោជិតខ្លួនឯងផ្ទាល់ត្រូវមានការយល់ដឹងចំពោះបញ្ហាសុខភាព និងប្រុងប្រយ័ត្នខ្ពស់ក្នុងការបំពេញការងារជាពិសេសការធ្វើដំណើរទៅមក ត្រូវមានការប្រុងប្រយ័ត្នខ្ពស់កុំឱ្យមានគ្រោះថ្នាក់ដែលនាំឱ្យខាតបង់ការងារ ពេលវេលា ថវិកា និងអាចបាត់បង់ដល់អាយុជីវិតទៀតផង។

ថ្ងៃអង្គារ ៤កើត ខែ មាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី១៣ខែកុម្ភៈ ឆ្នាំ២០២៤

**អគ្គនាយកបេឡាជាតិសន្តិសុខសង្គមស្តីទី**

**ម៉េង ហុង**

## ៦. ឧបសម្ព័ន្ធ

### ឧបសម្ព័ន្ធទី១

### បច្ចុប្បន្នភាពសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតផ្នែកហានិភ័យការងារ ផ្នែកថែទាំសុខភាព និងផ្នែកប្រាក់សោធន

| ល.រ | រាជធានី ខេត្ត | ឆ្នាំ2023 | | |
|---|---|---|---|---|
| | | សហគ្រាស | កម្មករនិយោជិត | ស្រី |
| 1 | ខេត្តបន្ទាយមានជ័យ | 446 | 13,575 | 8,046 |
| 2 | ខេត្តបាត់ដំបង | 1,109 | 9,886 | 4,882 |
| 3 | ខេត្តកំពង់ចាម | 420 | 37,373 | 30,407 |
| 4 | ខេត្តកំពង់ឆ្នាំង | 219 | 48,764 | 39,685 |
| 5 | ខេត្តកំពង់ស្ពឺ | 393 | 156,545 | 113,614 |
| 6 | ខេត្តកំពង់ធំ | 397 | 13,901 | 6,137 |
| 7 | ខេត្តកំពត | 216 | 14,576 | 9,343 |
| 8 | ខេត្តកណ្ដាល | 602 | 156,386 | 113,076 |
| 9 | ខេត្តកោះកុង | 78 | 12,696 | 7,748 |
| 10 | ខេត្តក្រចេះ | 318 | 9,161 | 3,905 |
| 11 | ខេត្តមណ្ឌលគិរី | 242 | 1,974 | 861 |
| 12 | រាជធានីភ្នំពេញ | 9,971 | 733,813 | 411,733 |
| 13 | ខេត្តព្រះវិហារ | 300 | 1,967 | 870 |
| 14 | ខេត្តព្រៃវែង | 210 | 3,656 | 2,782 |
| 15 | ខេត្តពោធិ៍សាត់ | 413 | 7,159 | 5,180 |
| 16 | ខេត្តរតនគិរី | 232 | 15,480 | 6,536 |
| 17 | ខេត្តសៀមរាប | 914 | 24,338 | 12,053 |
| 18 | ខេត្តព្រះសីហនុ | 436 | 63,570 | 31,585 |
| 19 | ខេត្តស្ទឹងត្រែង | 76 | 1,645 | 712 |
| 20 | ខេត្តស្វាយរៀង | 294 | 85,901 | 52,682 |
| 21 | ខេត្តតាកែវ | 284 | 65,665 | 50,267 |
| 22 | ខេត្តឧត្តរមានជ័យ | 170 | 3,525 | 1,587 |
| 23 | ខេត្តកែប | 69 | 794 | 490 |
| 24 | ខេត្តប៉ៃលិន | 146 | 1,725 | 915 |
| 25 | ខេត្តត្បូងឃ្មុំ | 275 | 10,501 | 5,013 |
| **សរុប** | | **18,230** | **1,494,576** | **920,109** |

## ❖ បច្ចុប្បន្នភាពសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតចុះបញ្ជិកាតាមប្រភេទពាណិជ្ជកម្ម

| ល.រ | លេខប្រភេទពាណិជ្ជកម្ម | ប្រភេទពាណិជ្ជកម្ម | ចំនួនសហគ្រាស | ចំនួនកម្មករនិយោជិត | |
|---|---|---|---|---|---|
| | | | | សរុប | ស្រី |
| 1 | 111 | ការដាំដុះដំណាំធញ្ញជាតិ (លើកលែងស្រូវ) ដំណាំសណ្តែកបន្លែ និងដំណាំសណ្តែងប្រេង | 47 | 5,864 | 2,422 |
| 2 | 112 | ការដាំដុះស្រូវ | 2 | 21 | 8 |
| 3 | 113 | ការដាំដុះបន្លែ និងដំណាំអម្បូរត្រសក់ផ្អែម ដំណាំយកឫស និងមើម | 11 | 83 | 40 |
| 4 | 114 | ការដាំដុះអំពៅ | 7 | 73 | 15 |
| 5 | 119 | ការដាំដុះដំណាំអាយុកាលខ្លីដទៃទៀត | 5 | 95 | 18 |
| 6 | 122 | ការដាំដុះផ្លែឈើតំបន់ត្រូពិច និងអនុតំបន់ត្រូពិច | 20 | 774 | 348 |
| 7 | 123 | ការដាំដុះដំណាំក្រូច | 3 | 18 | 14 |
| 8 | 124 | ការដាំដុះដំណាំហូបផ្លែ និងមានគ្រាប់ | 2 | 232 | 125 |
| 9 | 125 | ការដាំដុះដំណាំហូបផ្លែ និងគ្រាប់ ប្រភេទដើមឈើនិងចុល្លព្រឹក្សដទៃទៀត | 15 | 44 | 30 |
| 10 | 126 | ការដាំដុះដំណាំផ្លែដែលមានជាតិប្រេង | 3 | 735 | 188 |
| 11 | 127 | ការដាំដុះដំណាំសម្រាប់ផលិតភេសជ្ជៈ | 3 | 45 | 20 |
| 12 | 128 | ការដាំដុះរុក្ខជាតិគ្រឿងទេស រុក្ខជាតិយកក្លិន និងរុក្ខជាតិឱសថនិងថ្នាំពុល | 7 | 235 | 102 |
| 13 | 129 | ការដាំដុះដំណាំអាយុកាលវែងដទៃទៀត | 127 | 27,189 | 11,179 |
| 14 | 130 | ការបណ្តុះរុក្ខជាតិ | 3 | 14 | 11 |
| 15 | 141 | ការចិញ្ចឹមគោ និងក្របី | 31 | 2,193 | 837 |
| 16 | 145 | ការចិញ្ចឹមជ្រូក | 8 | 1,184 | 407 |
| 17 | 146 | ការចិញ្ចឹមបសុបក្សី | 14 | 71 | 47 |
| 18 | 149 | ការចិញ្ចឹមសត្វប្រភេទដទៃទៀត | 7 | 471 | 251 |
| 19 | 161 | សកម្មភាពគាំទ្រដល់ផលិតកម្មដំណាំ | 1 | 36 | 10 |
| 20 | 163 | សកម្មភាពក្រោយប្រមូលផលដំណាំ | 1 | 3 | 2 |
| 21 | 164 | ការកែច្នៃគ្រាប់ពូជសម្រាប់បណ្តុះ | 4 | 88 | 51 |
| 22 | 321 | វារីវប្បកម្មក្នុងទឹកប្រៃ | 0 | 0 | 0 |
| 23 | 322 | វារីវប្បកម្មក្នុងទឹកសាប | 9 | 49 | 30 |
| 24 | 729 | អាជីវកម្មរ៉ែលោហៈដែលមិនមែនដែក | 12 | 494 | 79 |
| 25 | 810 | ប្រតិបត្តិការយកថ្ម ខ្សាច់ និងដីឥដ្ឋ | 20 | 277 | 42 |
| 26 | 893 | សកម្មភាពផលិតអំបិល | 5 | 26 | 13 |
| 27 | 899 | សកម្មភាពផ្សេងទៀត នៃប្រតិបត្តិការនិងអាជីវកម្មធនធានរ៉ែ ដទៃទៀតដែលពុំបានរាប់បញ្ចូល | 6 | 398 | 31 |
| 28 | 910 | សកម្មភាពគាំទ្រសម្រាប់ការយកប្រេងកាតឆៅនិងឧស្ម័នធម្មជាតិ | 3 | 90 | 28 |
| 29 | 990 | សកម្មភាពគាំទ្រសម្រាប់ប្រតិបត្តិការធនធានរ៉ែផ្សេងទៀត | 2 | 8 | 2 |
| 30 | 1011 | សត្តឃាត និងការវេចខ្ចប់សាច់ (លើកលែងបសុបក្សី) | 3 | 28 | 14 |

| | | | | | |
|---|---|---|---|---|---|
| 31 | 1013 | ការកែច្នៃ និងថែរក្សាសាច់និងផលិតផលសាច់សត្វបសុបក្សី | 5 | 52 | 24 |
| 32 | 1021 | ការកែច្នៃនិងការរក្សាទុក នូវសាច់ត្រីនិងផលិតផលសាច់ត្រី (ស្រស់ បង្កក ឬក្លាសេ) | 4 | 31 | 5 |
| 33 | 1031 | ការកែច្នៃនិងការរក្សាទុក ផ្លែឈើនិងបន្លែ | 2 | 926 | 532 |
| 34 | 1032 | ផលិតកម្មផ្លែឈើនិងបន្លែច្រកកំប៉ុង | 13 | 608 | 282 |
| 35 | 1033 | ផលិតកម្មទឹកផ្លែឈើឬទឹកបន្លែ | 2 | 5 | 3 |
| 36 | 1039 | ផលិតកម្មទឹកផ្លែឈើឬទឹកបន្លែ ដទៃទៀតដែលពុំបានរាប់បញ្ចូល | 1 | 7 | 6 |
| 37 | 1042 | កម្មន្តសាលប្រេងដូង នំធ្វើពីសាច់ដូងស្ងួតអាហារ និងនំគ្រាប់តូចៗធ្វើពីសាច់ដូង | 1 | 8 | 8 |
| 38 | 1043 | កម្មន្តសាលប្រេងពីដូងប្រេង | 1 | 38 | 31 |
| 39 | 1051 | ការកែច្នៃទឹកដោះគោស្រស់និងកម្មន្តសាលនៃក្រែម | 3 | 596 | 84 |
| 40 | 1053 | កម្មន្តសាលការ៉េម និងការ៉េមប្រអប់ទឹកកកអនាម័យ ការ៉េមដើមនិងទឹកកក រសជាតិដទៃទៀត | 5 | 54 | 19 |
| 41 | 1061 | កម្មន្តសាល ផលិតផលពីការកិនគ្រាប់ធញ្ញជាតិ (លើកលែងអង្ករ/ពោត) | 1 | 79 | 41 |
| 42 | 1063 | ការកិនអង្ករ/ពោតនិងកម្មន្តសាលម្សៅពីអង្ករ/ពោត | 111 | 1,396 | 362 |
| 43 | 1071 | កម្មន្តសាលនំដុត | 63 | 1,128 | 521 |
| 44 | 1072 | កម្មន្តសាលស្ករ | 5 | 1,423 | 198 |
| 45 | 1073 | កម្មន្តសាលកាកាវសូកូឡានិងស្ករគ្រាប់ | 5 | 243 | 109 |
| 46 | 1074 | កម្មន្តសាលមីម៉ាការ៉ូនី មីសរសៃ មីកូស្កុស និងផលិតផលម្សៅមីស្រដៀងគ្នា | 27 | 956 | 354 |
| 47 | 1076 | កម្មន្តសាលកាហ្វេតែនិងឱសថរុក្ខជាតិសម្រាប់ឆុង | 1 | 2 | 1 |
| 48 | 1077 | កម្មន្តសាលគ្រឿងទេសដែលបានកែច្នៃ ទឹកជ្រលក់គ្រឿងផ្សំផ្សេង ៗ និងផលិតផលសម្រាប់ធ្វើម្ហូបផ្សេងទៀត | 21 | 246 | 105 |
| 49 | 1079 | កម្មន្តសាលផលិតផលចំណីអាហារផ្សេងទៀត ដែលពុំបានរាប់បញ្ចូល | 18 | 881 | 367 |
| 50 | 1080 | កម្មន្តសាលចំណីសត្វរៀបចំរួច | 23 | 7,693 | 3,911 |
| 51 | 1101 | ការបិត ការបន្សុទ្ធ និងការលាយស្រាស្ពីរីត | 5 | 168 | 46 |
| 52 | 1102 | កម្មន្តសាលស្រា (វ៉ាញ) | 1 | 2 | 2 |
| 53 | 1103 | កម្មន្តសាលស្រាម៉ល់និងម៉ល់ | 14 | 4,674 | 1,121 |
| 54 | 1104 | កម្មន្តសាលភេសជ្ជៈគ្មានជាតិអាកុល | 145 | 2,878 | 816 |
| 55 | 1105 | កម្មន្តសាលទឹកបរិសុទ្ធ និងទឹករ៉ែ | 126 | 1,206 | 551 |
| 56 | 1201 | កម្មន្តសាលបារីនិងស៊ីហ្គា | 9 | 1,165 | 320 |
